

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឆ្នាំទី២
# នៃដំណើរឆ្ពោះទៅសម្រេច
# ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០

បោះពុម្ពនៅ រាជធានីភ្នំពេញ ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩
ត្រូវនឹង ខែធ្នូ ឆ្នាំ ២០២៥

អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល

# មាតិកា


១. មតិស្វាគមន៍

២. សមិទ្ធផលនៃកិច្ចការងារក្នុង និងក្រៅប្រទេស ទំព័រ ១

២.១. កិច្ចការងារក្នុងស្រុក ទំព័រ ១

២.១.១. សន្តិសុខសង្គម ទំព័រ ១

២.១.២. ការលើកកម្ពស់វិស័យសេដ្ឋកិច្ច ទំព័រ ៣

២.១.៣. ការកសាងហេដ្ឋារចនាសម្ព័ន្ធចម្បងៗ ទំព័រ ១៦

២.១.៤. ការអភិវឌ្ឍវិស័យសង្គមកិច្ច ទំព័រ ១៩

២.២. កិច្ចការងារការបរទេស និងទំនាក់ទំនងអន្តរជាតិ ទំព័រ ២១

២.២.១. ការទូតនយោបាយ ទំព័រ ២១

២.២.២. ការទូតសេដ្ឋកិច្ច ទំព័រ ២៣

២.២.៣. ការទូតពង្រឹងមិត្តភាពចាស់ ពង្រីកមិត្តភាពថ្មី ទំព័រ ២៥

៣. កម្មវិធីគោលនយោបាយអាទិភាពទាំង៦ ទំព័រ ២៩

៣.១. ផ្តល់ការថែទាំសុខភាពឆ្ពោះទៅការគ្របដណ្តប់ជាសកល ទំព័រ ២៩

៣.២. បណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈដល់កូនអ្នកក្រីក្រនិង ងាយរងហានិភ័យ ទំព័រ ៣២

៣.៣. ពង្រឹងកម្មវិធីជាតិជំនួយសង្គមសម្រាប់គ្រួសារក្រីក្រនិងងាយ រងហានិភ័យ ទំព័រ ៣៣

៣.៤. យុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ ទំព័រ ៣៤

៣.៥. លើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងការរក្សាលំនឹងតម្លៃកសិផល ទំព័រ ៣៥

៣.៦. ការដាក់ពង្រាយអ្នកជំនាញបច្ចេកទេសកសិកម្មតាមឃុំសង្កាត់ ទំព័រ ៣៧

៤. វិធានការគន្លឹះទាំង៥ ទំព័រ ៣៨

១. ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ ទំព័រ ៣៩

២. ការលើកកម្ពស់គុណភាពអប់រំ ទំព័រ ៤០

៣. ការលើកកម្ពស់គុណភាពសេវាសុខាភិបាល ទំព័រ ៤១

៤. ការពង្រឹងការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាពដើម្បីប្រយុទ្ធ ប្រឆាំងនឹងការជួញដូរនិងប្រើប្រាស់គ្រឿងញៀន ទំព័រ ៤២

៥. ការពង្រឹងនិងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ ទំព័រ ៤៤

៥. សេចក្តីសន្និដ្ឋាន ទំព័រ ៤៥

# ១. មតិស្វាគមន៍



អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល (អ.អ.រ.) សូមគោរពស្វាគមន៍យ៉ាងកក់ក្តៅចំពោះ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា និងបងប្អូនជនរួមជាតិទាំងក្នុងនិងក្រៅប្រទេស ដែលចាប់អារម្មណ៍អានសៀវភៅ **ឆ្នាំទី២ នៃដំណើរឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០** ដែលចងក្រងអំពីសមិទ្ធផលរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ក្លាយជាប្រទេសមានចំណូលខ្ពស់។

តាមរយៈកូនសៀវភៅនេះ អ.អ.រ. មានកិត្តិយសសូមរំលេចជូននូវសមិទ្ធផលលេចធ្លោសំខាន់ៗ ដែលរាជរដ្ឋាភិបាលបន្តវេនសម្រេចបានក្នុង ឆ្នាំ២០២៥ ជាពិសេសការប្តេជ្ញាចិត្តរក្សាឱ្យបានគង់វង្សនូវសមិទ្ធផលនានាដែលកសាងដោយរាជរដ្ឋាភិបាលអាណត្តិមុនៗដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងការប្តេជ្ញាចិត្តកសាងសមិទ្ធផលថ្មីៗបន្ថែមទៀតជូនជាតិមាតុភូមិ។

ជាក់ស្តែង ក្នុងអំឡុងពេលដែលកម្ពុជាទទួលរងការរំលោភបំពានយ៉ាងកំរោលពីសំណាក់យោធាថៃ រាជរដ្ឋាភិបាលកម្ពុជា ដោយឈរលើគោលជំហរសន្តិភាពនិយម និងផ្តល់តម្លៃខ្ពស់ចំពោះជីវិតមនុស្ស និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋជាធំ បានខិតខំប្រឹងប្រែងដោយដៃម្ខាងការពារសន្តិភាពតាមរយៈការប្រើប្រាស់គ្រប់មធ្យោបាយការទូតដើម្បីសម្រេចបានបទឈប់បាញ់ និងដៃម្ខាងទៀត ខំប្រឹងការពារអធិបតេយ្យភាព និងបូរណភាពទឹកដី ដោយផ្អែកលើដំណោះស្រាយដោយសន្តិវិធី តាមរយៈការប្រើប្រាស់យន្តការបច្ចេកទេស ដោយអនុលោមតាមសន្ធិសញ្ញា អនុសញ្ញា និងច្បាប់អន្តរជាតិ។ ក្រៅពីនោះ រាជរដ្ឋាភិបាលនៅតែបន្តអភិវឌ្ឍប្រទេសជាតិស្របតាមគោលនយោបាយដែលបានដាក់ចេញ ដោយអាចសម្រេចសមិទ្ធផលសំខាន់ៗគួរឱ្យកត់សម្គាល់ជាច្រើន ជាពិសេសការងារពាណិជ្ជកម្ម (ជោគជ័យនៃការ

ចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មបដិការរវាងកម្ពុជានិងសហរដ្ឋអាម៉េរិកធ្លាក់ចុះពី៤៩% មកត្រឹម១៩%) ការទាក់ទាញអ្នកវិនិយោគ ការកសាងគ្រប់គ្រងនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធនិងប្រព័ន្ធគាំពារសង្គម រក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបានធ្វើកំណែទម្រង់លើវិស័យធំៗជាច្រើន ដូចជា សុខាភិបាល រដ្ឋបាលសាធារណៈ អប់រំ កសិកម្ម ការលើកកម្ពស់គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព គុណភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ និងការពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់អភិវឌ្ឍន៍លើគ្រប់វិស័យ។

ឆ្លៀតក្នុងឱកាសនេះ អ.អ.រ. សូមថ្លែងអំណរគុណដល់អ្នកនាំពាក្យនៃក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ចំពោះកិច្ចសហការដ៏សកម្មក្នុងការផ្តល់ព័ត៌មានលើកិច្ចការងារជាតិនិងអន្តរជាតិបានយ៉ាងពិស្តារ និងគ្រប់ជ្រុងជ្រោយ។

ជាទីបញ្ចប់ តាមរយៈកូនសៀវភៅស្តីពីលទ្ធផលការងារសង្ខេប ឆ្នាំទី២នេះ អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល សូមសម្តែងនូវសេចក្តីគោរព និងការដឹងគុណដ៏ជ្រាលជ្រៅបំផុត គោរពជូនថ្នាក់ដឹកនាំកំពូលៗគ្រប់រូប មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ជនរួមជាតិទាំងក្នុងនិងក្រៅប្រទេស រួមទាំងដៃគូអភិវឌ្ឍន៍ និងតួអង្គពាក់ព័ន្ធទាំងអស់ដែលបាននិងបន្តចូលរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ហើយបានផ្តល់ជំនឿទុកចិត្តនិងការគាំទ្រដ៏ធំធេងចំពោះរាជរដ្ឋាភិបាលនៅគ្រប់ដំណាក់កាល។

រាជធានីភ្នំពេញ ថ្ងៃពុធ ១២កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
ត្រូវនឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
ប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល

**ប៉ែន បូណា**

# ២. សមិទ្ធផលនៃកិច្ចការខាងក្នុង និងក្រៅប្រទេស

## ២.១ កិច្ចការខាងក្នុងស្រុក

### ២.១.១. សន្តិសុខសង្គម

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីបន្តវេន បាននិងកំពុងបន្តជំហរដាច់ខាតនិងម៉ឺងម៉ាត់ក្នុងការរក្សាសន្តិភាពនិងសមិទ្ធផលនានាដែលជាកេរដំណែលដ៏ថ្លៃថ្លារបស់រាជរដ្ឋាភិបាលអាណត្តិមុនៗ ដែលដឹកនាំដោយ អតីតនាយករដ្ឋមន្ត្រី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសការប្តេជ្ញាការពារអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី និងសុខសន្តិភាព ដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍប្រទេស។ ប្រជាពលរដ្ឋកម្ពុជាបានឃើញយ៉ាងច្បាស់ចំពោះគោលជំហររបស់ប្រមុខថ្នាក់ដឹកនាំកម្ពុជានៅក្នុងសករាជ **តេជោ-ធិបតី** ដែលពុះពារគ្រប់ឧបសគ្គនិងលះបង់គ្រប់បែបយ៉ាងដើម្បីជាតិ មាតុភូមិ និងប្រជាពលរដ្ឋខ្មែរ។




តាមរយៈយុទ្ធសាស្ត្រ “ស្ងាត់តែមិនស្ងៀម” របស់សម្តេចធិបតីនាយករដ្ឋមន្ត្រី រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងការពារសន្តិភាព និងអធិបតេយ្យភាព បូរណភាពទឹកដី ជាពិសេសក្នុងអំឡុងពេលដែលប្រទេសជាតិរងការរំលោភបំពានដ៏គឃ្លើនរបស់ប្រទេសថៃ ដោយសម្រេចបានកិច្ចព្រមព្រៀងបទឈប់បាញ់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ នៅទីក្រុងពុត្រាចាយ៉ា ក្រោមការផ្តួចផ្តើមនិងជួយជ្រោមជ្រែងពីសំណាក់ប្រធានាធិបតីសហរដ្ឋអាម៉េរិក និងនាយករដ្ឋមន្ត្រីប្រទេសម៉ាឡេស៊ី និងជាប្រធានអាស៊ានប្តូរវេន និងការចូលរួមយ៉ាងសកម្មរបស់សាធារណរដ្ឋប្រជាមានិតចិន និង សេចក្តីថ្លែងការណ៍រួមស្តីពីសន្តិភាព ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ នៅទីក្រុងកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ដែលចុះហត្ថលេខាដោយ នាយករដ្ឋមន្ត្រីកម្ពុជានិងថៃ ក្រោមវត្តមានជាសាក្សីរបស់ប្រធានាធិបតីសហរដ្ឋអាមេរិក និងនាយករដ្ឋមន្ត្រីម៉ាឡេស៊ី និង សេចក្តីប្រកាសរួមថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ដែលឈានដល់ការអនុវត្តបទឈប់បាញ់ជាថ្មី។ រាជរដ្ឋាភិបាលកម្ពុជា ដៃម្ខាង

ប្រើសិទ្ធិការពារខ្លួនការពារបូរណភាពទឹកដីនៅលើសមរភូមិជួរមុខ ដៃម្ខាងពុះពារក្នុងយន្តការការទូតដើម្បីបញ្ចប់សង្គ្រាមដោយសន្តិវិធី ជៀសវាងនិងកាត់បន្ថយការបង្ហូរឈាម ចំណែកបេះដូងឈរឱបក្រសោបពលរដ្ឋភៀសសឹកកម្ពុជា ជាងកន្លះលាននាក់។

ចំណែកកិច្ចការងារព្រំដែនទិសខាងកើត បន្ថែមលើការងារបោះបង្គោលព្រំដែន រាជរដ្ឋាភិបាលបាននិងកំពុងបន្តការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងការកសាងផ្លូវក្រវាត់ព្រំដែន រៀបចំតំបន់



រស់នៅជូនប្រជាពលរដ្ឋដែលខ្វះដីធ្លីពិតប្រាកដអាចទៅរស់នៅតំបន់ព្រំដែន ជំរុញនិងការពារធនធានធម្មជាតិនៅតំបន់នោះ និងដាក់ចេញនូវកញ្ចប់លើកទឹកចិត្តវិនិយោគនៅតាមព្រំដែន។ សមិទ្ធផលជាក់ស្តែងមួយក្នុងចំណោមសមិទ្ធផលជាក់ស្តែងដែលសម្រេចបានជាច្រើននោះគឺ ផ្លូវតភ្ជាប់ក្រវាត់ព្រំដែនកម្ពុជា-វៀតណាម ដែលមានតម្លៃជាយុទ្ធសាស្ត្រ ហើយបាននិងកំពុងសម្រេចចេញជារូបរាងយ៉ាងល្អរឹងមាំរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត**។

គិតមកត្រឹមថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ ក្រុមការងារបានបោសសម្អាតមីន-យុទ្ធភណ្ឌមិនទាន់ផ្ទុះលើផ្ទៃដីទំហំ ៤ ៤១៥ ០០០ម៉ែត្រការ៉េ ស្មើនឹង ៧០,៦៤ភាគរយ នៃផ្ទៃដីសរុបដែលជាមុខសញ្ញានៃការដ្ឋានស្ថាបនាផ្លូវក្រវាត់ព្រំដែនកម្ពុជា-វៀតណាម ដោយបានរកឃើញកាកសំណល់សង្គ្រាមមានដូចជា គ្រាប់មីនគ្រប់ប្រភេទចំនួន ៧៩គ្រាប់ ដែលក្នុងនោះមានគ្រាប់បែកចង្កោមចំនួន ៣៥គ្រាប់។



ការកសាងផ្លូវក្រវាត់ព្រំដែនសម្រេចបានលទ្ធផលធំធេង ដោយកសាងតួផ្លូវបានប្រវែង ១២៤គីឡូម៉ែត្រ និងក្រាលល្បាយថ្មសម្រេចជាស្ថាពរប្រវែង ៨៥,៩០គីឡូម៉ែត្រ។ ជាលទ្ធផលរួមនៃដំណើរកសាងផ្លូវក្រវាត់ព្រំដែននេះ គឺសម្រេចបានប្រមាណ ៥៣,៣០% នៃផែនការរួម។

## ២.១.២. ការលើកកម្ពស់វិស័យសេដ្ឋកិច្ច

ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច កម្ពុជាបានរក្សាកំណើនជាតិ ក្នុងអត្រា ៥% នៅឆ្នាំ២០២៥ ដែលនេះបានឆ្លុះបញ្ចាំងនូវភាពធន់នៃសេដ្ឋកិច្ចកម្ពុជាក្នុងបរិការណ៍ដែលត្រូវប្រឈមនឹងការវិវត្តដ៏ស្មុគស្មាញនៃសភាពការណ៍ ក្នុងតំបន់ និងពិភពលោក និងកត្តាអវិជ្ជមានជាច្រើនទៀត ក្នុងនោះរួមទាំងការបិទខ្ទប់ច្រកព្រំដែនគោកកម្ពុជា-ថៃ។

កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរថ្មី អាកាសយានដ្ឋានអន្តរជាតិតេជោ និងផ្លូវល្បឿនលឿន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចកម្ពុជា។

ជាឧទាហរណ៍ជាក់ស្តែង កំពង់ផែស្វយ័តក្រុងព្រះសីហនុ សម្រេចបានការដឹកជញ្ជូនទំនិញឆ្លងកាត់ផែ (នាំចូល និងនាំចេញ) មានចំនួនសរុប ៩,៦០លានតោន និងទទួលបានចំណូលសរុបប្រមាណ ១១០,៣៨លានដុល្លារអាម៉េរិក កើនឡើង ២៤,១២% ដែលមានចំនួន ៨៨,៩៤លានដុល្លារអាម៉េរិក។ ជាមួយគ្នានេះ កំពង់ផែស្វយ័តភ្នំពេញ សម្រេចបានការដឹកជញ្ជូនទំនិញឆ្លងកាត់ផែ (នាំចូល និងនាំចេញ) មានចំនួនសរុប ៤,៥១លានតោន និងទទួលបានចំណូលសរុបប្រមាណ ៤៣,៤៥ លានដុល្លារអាម៉េរិក កើនឡើង ១៦,៦០% ដែលមានចំនួន ៣៧,២៧លានដុល្លារអាម៉េរិក។ រីឯផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា កែលម្អការតភ្ជាប់ភស្តុភារ និងជំរុញសកម្មភាពនាំចេញ-នាំចូល ដោយបានតភ្ជាប់ការដឹកជញ្ជូនទំនិញរវាងប៉ូលសេដ្ឋកិច្ចភ្នំពេញ និងប៉ូលសេដ្ឋកិច្ចខេត្តព្រះសីហនុ។




### ក. លទ្ធផលការងារពាណិជ្ជកម្ម

ទោះបីកម្ពុជាជួបវិបត្តិជម្លោះព្រំដែននិងទទួលរងការរំលោភបំពានយ៉ាងកំរោលពីសំណាក់យោធាថៃ

រាជរដ្ឋាភិបាលកម្ពុជានៅរក្សាបានចរន្តពាណិជ្ជកម្មនាំចេញ-នាំចូលរបស់ខ្លួនដោយរក្សាបានកំណើនសេដ្ឋកិច្ចបានល្អ។ ជាក់ស្តែងក្នុងឆ្នាំ២០២៥ កម្ពុជារក្សាបានទំហំពាណិជ្ជកម្មនាំចេញនិងនាំចូលសរុប ៦៥,២៤ពាន់លានដុល្លារអាម៉េរិក កើនឡើង ៩,៧៩ពាន់លានដុល្លារអាម៉េរិក ស្មើនឹង ១៨% បើប្រៀបធៀបនឹង ឆ្នាំ២០២៤ (៥៥,៤៥ពាន់លានដុល្លារអាម៉េរិក)។ ជាមួយការទទួលបានការកាត់បន្ថយអត្រាពន្ធគយបដិការមកត្រឹម ១៩% លើទំនិញនាំចេញទៅសហរដ្ឋអាម៉េរិក នឹងចូលរួមចំណែករក្សាភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការទាក់ទាញលើការវិនិយោគថ្មីៗ និងជំរុញដល់កំណើនពាណិជ្ជកម្មនាំចេញរបស់កម្ពុជាបន្ថែមទៀត។



ក្នុងឆ្នាំ២០២៥នេះ ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិមានតម្លៃសរុប ៣១,២៨ ពាន់លានដុល្លារអាម៉េរិក កើនឡើង ៤,៥៣ពាន់លានដុល្លារអាម៉េរិក ស្មើនឹង ១៨% បើប្រៀបធៀបនឹងឆ្នាំ ២០២៤ (២៦,៧៥ពាន់លានដុល្លារអាម៉េរិក)។ ទីផ្សារអន្តរជាតិដែលកម្ពុជានាំចេញ រួមមាន សហរដ្ឋអាម៉េរិក កាណាដា អេស្ប៉ាញ ចក្រភពអង់គ្លេស ហូឡង់ អាល្លឺម៉ង់ ជប៉ុន អូស្ត្រាលី បែលហ្ស៊ិក បារាំង ចិន ថៃ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី កោះតៃវ៉ាន់ វៀតណាម កូរ៉េខាងត្បូង ឡាវ ហ្វាំងឡង់ ហុងកុង។ ទំនិញសំខាន់ៗនាំចេញរួមមាន សម្លៀកបំពាក់ សម្ភារៈធ្វើដំណើរ ស្បែកជើង ស្រូវ បន្ទះសូឡា ម៉ាស៊ីនបរិធាន និងសម្ភារៈអគ្គិសនី សំបកកង់រថយន្ត ដំឡូងមី ជ័រកៅស៊ូ អង្ករ វាយនភណ្ឌ ស្វាយចន្ទី ទោចក្រយាន



ក្តារកុងប្លាកេ ចេក ស្វាយ ស្ករអំពៅ ពោត ម្រេច ផ្លែមៀន ថ្នាំជក់ ផលិតផលជលផល និងផលិតផលផ្សេងទៀត។ល។

ចំពោះការនាំចូលក្នុងឆ្នាំ២០២៥ ការនាំចូលមានតម្លៃសរុប ៣៣,៩៦ពាន់លានដុល្លារអាម៉េរិក កើនឡើង ៥,២៦ពាន់លានដុល្លារអាម៉េរិក ស្មើនឹង ១៨% បើប្រៀបធៀបនឹងឆ្នាំ២០២៤ (២៨,៧០ពាន់លានដុល្លារអាម៉េរិក) ទំនិញដែលកម្ពុជានាំចូលជាវត្ថុធាតុដើមមានដូចជា វាយនភណ្ឌជាវត្ថុធាតុដើម គ្រឿងអេឡិចត្រូនិកនិងសម្ភារៈអគ្គិសនី សម្ភារៈសំណង់ ប្រេងឥន្ធនៈ ឧស្ម័ន រថយន្ត ដែកនិងដែកថែប ក្រដាសនិងក្រដាសកាតុង គ្រឿងឧបភោគបរិភោគ ជីកសិកម្មនិងថ្នាំសម្លាប់សត្វល្អិត ចរន្តអគ្គិសនី ផលិផលឱសថនិងអាហារបំប៉ន ស៊ីម៉ង់ត៍ ស្រាបៀរនិងស្រាចម្រុះ និងគ្រឿងសម្អាង។ល។

**សម្រាប់វិស័យឧស្សាហកម្ម** រាជរដ្ឋាភិបាលអាណត្តិទី៧ នៃរដ្ឋសភា សម្រេចបានវឌ្ឍនភាពគួរជាទីមោទនៈក្នុងបេសកកម្មពង្រឹងនិងពង្រីកមូលដ្ឋានឧស្សាហកម្ម សហគ្រាសធុនតូច និងមធ្យម



សេដ្ឋកិច្ចក្រៅប្រព័ន្ធ និងការគាំទ្រផ្សេងៗជាច្រើន ដូចជា ការកសាងសហគ្រិនភាព ការពង្រឹងសមត្ថភាពផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ និងការពង្រីកសេវាផ្គត់ផ្គង់ទឹកស្អាតទូទាំងប្រទេស។ ខាងក្រោមគឺជាជោគជ័យជាជំហានៗក្នុងការធ្វើកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ជាសេនាធិការ បានប្រែក្លាយគោលនយោបាយជាតិឱ្យចេញទៅជាសកម្មភាពជាក់ស្តែងសម្រាប់ប្រជាពលរដ្ឋនិងបន្តជំរុញឧស្សាហូបនីយកម្មជាសសរស្តម្ភនៃកំណើនសេដ្ឋកិច្ច និងការបង្កើតការងារ។ សមិទ្ធផលជាក់ស្តែងគួរឱ្យកត់សម្គាល់មួយចំនួនក្នុងចំណោមសមិទ្ធផលជាច្រើនដែលសម្រេចបានក្នុងពេលកន្លងមកមានដូចជា៖

__ឧស្សាហកម្មធុនធ្ងន់__ - គិតត្រឹមខែតុលា ឆ្នាំ២០២៥៖

➢ កម្ពុជាមានរោងចក្រធុនធ្ងន់ចំនួន ២ ៩០៤មូលដ្ឋាន កើនឡើងចំនួន ៥៥៩មូលដ្ឋាន បើ

ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤។ វិស័យឧស្សាហកម្មកំពុងផ្តល់ការងារចំនួនជាង ១,២៥លាន កន្លែង (ស្ត្រី ៧១,៧៧%) កើនឡើង ១១៣ ៣៤៣កន្លែង។

➢ ទុនវិនិយោគសរុបកើនឡើងដល់ ២៣,៤៨ពាន់លានដុល្លារអាម៉េរិក ពោលគឺកើន ៣,៣៤ ពាន់លានដុល្លារ (១៤,២៥%) បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ប្រភពទុនវិនិយោគធំជាងគេគឺប្រទេសចិន ខណៈដែលកម្ពុជាឈរក្នុងលំដាប់លេខ២ ដោយរួមចំណែកប្រមាណ ៣,៩០ពាន់លានដុល្លារអាម៉េរិក (១៦,៦%) នៃទុនវិនិយោគសរុប។

➢ ដើម្បីទាក់ទាញ និងកសាងទំនុកចិត្តរបស់អ្នកវិនិយោគ កម្ពុជាបានធ្វើពិពិធកម្មពីឧស្សាហកម្មអតិពលកម្ម ទៅជាឧស្សាហកម្មដែលបង្កើតតម្លៃបន្ថែមខ្ពស់ ដោយផ្អែកលើបច្ចេកវិទ្យា និងស្វ័យប្រវត្តិកម្ម ក្នុងនោះរួមមាន ឧស្សាហកម្មយានយន្ត ការផលិតគ្រឿងបង្គុំ និងផលិតផលពាក់កណ្តាលសម្រេចបន្ថែមលើឧស្សាហកម្មប្រពៃណី ដូចជាវិស័យកាត់ដេរសម្លៀកបំពាក់ និងវាយនភណ្ឌ ជាដើម។

**សហគ្រាសធុនតូច និងមធ្យម** - បន្ថែមលើឧស្សាហកម្មធុនធ្ងន់ រាជរដ្ឋាភិបាលបន្តគាំទ្រ និងថែបំប៉នសហគ្រាសធុនតូច និងមធ្យម ជាមូលដ្ឋានគ្រឹះសម្រាប់កំណើនប្រកបដោយបរិយាបន្ន។ គិតត្រឹមខែតុលា ឆ្នាំ២០២៥៖



➢ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានចុះបញ្ជីសហគ្រាសធុនតូច និងមធ្យមចំនួន ៤៤ ៥២៨មូលដ្ឋាន ដែលកំពុងផ្តល់ការងារប្រមាណ ៤៨៨ ៦២៤កន្លែង និងមានសហគ្រិនស្ត្រីចំនួន ៨ ៥៧៤នាក់។

➢ សហគ្រាសធុនតូច និងមធ្យមជាច្រើនក៏បានឆ្លើយតបនឹងការអំពាវនាវរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់គុណភាព ស្តង់ដា និងផលិតភាព ដើម្បីបំពេញតម្រូវការក្នុងស្រុក និងជំរុញការនាំចេញទៅទីផ្សារអន្តរជាតិ។

➢ ក្រោយសម្ពោធដាក់ឱ្យដំណើរការ ថ្នាលឌីជីថលចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានទទួលពាក្យស្នើសុំចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធចំនួនជាង ២៣ម៉ឺននាក់។ បាននិងកំពុងសម្របសម្រួលរៀបចំកញ្ចប់អត្ថប្រយោជន៍ សម្រាប់អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលបានចុះឈ្មោះលើថ្នាលឌីជីថល ដើម្បីអាចមានលទ្ធភាពទទួលសេវាហិរញ្ញវត្ថុផ្លូវការ អត្ថប្រយោជន៍របបសន្តិសុខសង្គម ការបណ្តុះបណ្តាលជំនាញ សេវាគាំពារសង្គម ការលើកលែងកាតព្វកិច្ចពន្ធ និងការអនុគ្រោះពន្ធជាដើម។

ដើម្បីធានាបានការជំរុញពិពិធកម្មឧស្សាហកម្ម និងពង្រឹងភាពប្រកួតប្រជែងសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅទូទាំងប្រទេស ក្រសួងបានសម្របសម្រួលនិងបង្កើនកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ដូចជា សហគ្រិនខ្មែរ គ្រឹះស្ថានហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ ធ្វើការកសាងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពដ៏រឹងមាំមួយ ដែលអាចធ្វើសមាហរណកម្មសហគ្រាសធុនតូចនិងមធ្យមចូលទៅក្នុងខ្សែច្រវាក់តម្លៃនៃឧស្សាហកម្មធុនធំទាំងការផលិតនិងការចែកចាយ ការធ្វើទីផ្សារនិងប្រេនឌីង និងការលក់ផលិតផលសម្រាប់ឧស្សាហកម្មធុនធំ។

**សេវាទឹកស្អាត**- ធានាបានការផ្តល់សេវាទឹកស្អាតដែលអាចជឿទុកចិត្តបានសម្រាប់ទាំងអស់គ្នា នៅតែជាអាទិភាពជាតិ តាមរយៈការវិនិយោគលើការពង្រីកហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងបណ្តាញទឹកស្អាត ដើម្បីផ្គត់ផ្គង់ជូនប្រជាពលរដ្ឋឱ្យបាន ១០០% នៅឆ្នាំ២០៣០ ដូចបានកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១៖ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។

សម្រាប់អាណត្តិទី៧ រាជរដ្ឋាភិបាលបាននិងកំពុងពង្រឹងទាំងសមត្ថភាពផលិត និងពង្រឹងប្រសិទ្ធភាពសេវាផ្គត់ផ្គង់ទឹកស្អាតនៅទូទាំងប្រទេស។ គិតត្រឹមខែកញ្ញា ឆ្នាំ២០២៥៖



➢ រាជរដ្ឋាភិបាលផ្តល់អាជ្ញាបណ្ណសេវាផ្គត់ផ្គង់ទឹកស្អាតចំនួន ៤៦០ ក្នុងនោះរដ្ឋាករទឹកមាន ១៤អាជ្ញាបណ្ណ និងប្រតិបត្តិករឯកជនចំនួន ៤៤៦អាជ្ញាបណ្ណ

➢ កសាងបណ្តាញចែកចាយទឹកស្អាតប្រវែង ៣៩ ៧១៦គីឡូម៉ែត្រ គ្របដណ្តប់ ៧ ៩៤៦ភូមិ ក្នុងចំណោម ១០ ៧៨៣ភូមិ នៃតំបន់សេវា និងភ្ជាប់បណ្តាញបានចំនួនប្រមាណជាង ១,៥៤លានគ្រួសារ នៅទូទាំងប្រទេស កើនឡើង ២៦៦ ៧៧៨គ្រួសារ (២០,៩%) បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

កំណើននៃបរិមាណផលិត បណ្តាញចែកចាយ តំបន់សេវា និងចំនួនគ្រួសារដែលបានតភ្ជាប់បណ្តាញទឹកស្អាតប្រើប្រាស់ទាំងនេះ ត្រូវបានគាំទ្រដោយការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជារោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងទាំង ៣ ដំណាក់កាល ដែលប្រើប្រាស់ថវិកាប្រមាណ ៦៦០ លានដុល្លារ រោងចក្រទឹកស្អាតតាខ្មៅ និងស្ថានីយ៍បូមទឹកនៅកោះនរាថ្មីសម្រាប់ធានាការផ្គត់ផ្គង់សម្រាប់តំបន់ភាគខាងត្បូងទីក្រុងភ្នំពេញ និងតំបន់អាកាសយានដ្ឋានអន្តរជាតិតេជោ ព្រមទាំងការសម្តោចដាក់ឱ្យដំណើរការជាផ្លូវការរោងចក្រ បណ្តាញចែកចាយ និងបរិក្ខារគាំទ្រវិស័យទឹកស្អាតតាមបណ្តារាជធានី-ខេត្តជាបន្តបន្ទាប់។



**ការនាំចេញផលិតផលកសិកម្ម៖** ក្នុងរយៈពេល ១០ខែ ឆ្នាំ២០២៥ កម្ពុជាបាននាំចេញផលិតផលកសិកម្ម រួមមាន ផលិតផលដំណាំ ផលិតផលមានដើមកំណើតពីសត្វ សត្វរស់ ចំណីសត្វ ផលិតផលជលផល ផលិតផលជ័រកៅស៊ូ និងផលអនុផលព្រៃឈើ បានចំនួន ១១,៨៩លានតោន ដែលគិតជាទឹកប្រាក់សរុបចំនួន ៥,២៣ពាន់លានដុល្លារអាម៉េរិក មានការកើនឡើងចំនួន ២១,៧២% បើធៀបនឹងការនាំចេញក្នុងរយៈពេល១០ខែ ឆ្នាំ២០២៤ មានចំនួនប្រមាណ ៤,៣ពាន់លានដុល្លារអាម៉េរិក។ ក្នុងឆ្នាំ២០២៥ កម្ពុជាបាននាំចេញអង្ករចំនួនសរុប ៩៤០ពាន់តោន គិតជាទឹកប្រាក់ប្រមាណ ៦០២លាន

ដុល្លារអាមេរិក ធៀបនឹងឆ្នាំ២០២៤ កើនឡើង ៤៥,៥៩% និងនាំចេញស្រូវសរុបប្រមាណ ៦,៨៥លាន



តោន គិតជាទឹកប្រាក់ប្រមាណជាង ១,៥៧ ពាន់លានដុល្លារអាមេរិក កើនឡើង ៣២,៤៣% ធៀបនឹងឆ្នាំ២០២៤។

បន្ថែមលើនេះ ដើម្បីជំរុញការនាំចេញផលិតផលសក្តានុពលរបស់កម្ពុជា ដែលភាគច្រើនជាកសិផល រាជរដ្ឋាភិបាលកម្ពុជាមានក្រសួងពាណិជ្ជកម្មជាសេនាធិការ បានបង្កើតក្រុមការងារជំរុញការនាំចេញ។ ខាងក្រោម ជាសមិទ្ធផលដែលក្រុមការងារនេះសម្រេចបានកន្លងមក៖

- បានសម្របសម្រួលការចុះអនុស្សរណៈ និងកិច្ចព្រមព្រៀងចំនួន ៣៩ រវាងដៃគូបញ្ជាទិញ (អាស៊ាន និងអឺរ៉ុប រួមមាន បារាំង ហូឡង់ អូស្ត្រាលី ជប៉ុន និងចិន) និងអ្នកផ្គត់ផ្គង់ក្នុងស្រុកក្នុងគោលដៅធានាស្ថិរភាពនៃខ្សែច្រវាក់ផ្គត់ផ្គង់ និងពង្រឹងការទទួលស្គាល់គុណភាពទំនិញកម្ពុជាលើទីផ្សារពិភពលោក

- រយៈពេល១០ខែ ឆ្នាំ២០២៥នេះ កម្ពុជាបានជំរុញការនាំចេញគ្រាប់ស្វាយចន្ទី ៦៣៤ពាន់តោន និងស្វាយចន្ទីកែច្នៃចំនួន ៣ម៉ឺនកញ្ចប់ ដំណាប់ស្វាយស្ងួតចំនួន ១តោន ដំឡូងមីក្រៀមប្រមាណ ១,៤លានតោន កើនឡើងចំនួន ៦០,៩១% និងម្សៅដំឡូងមីកើនឡើងចំនួន ៨២,៥៩% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៤ និងត្រៀមបម្រុងនាំចេញ ២០០ពាន់តោន ឆ្នាំ២០២៥-២០២៦ និងទុរេនស្រស់ចំនួន ១៥ ០០០តោន សម្រាប់ទីផ្សារចិន។

- បានជំរុញការដាក់លក់ផលិតផលខ្មែរនៅតាមផ្សារលក់រាយ រួមមាន Family Mart នៅជប៉ុន ដែលមាន ១ ២០០ហាង ទីផ្សារ 7-Eleven នៅជប៉ុន និងម៉ាឡេស៊ី ទីផ្សារ Aldi នៅអូស្ត្រាលី និងទីផ្សារ Intermarche E.Leclerc, and Auchan នៅអឺរ៉ុប

➢ បានជំរុញភាពជាដៃគូ និងពង្រីកទីផ្សារដែលធ្វើឱ្យមានការទទួលបានការបញ្ជាទិញជាថ្មី នៅ បារាំង ហូឡង់ អូស្ត្រាលី ជប៉ុន ម៉ាឡេស៊ី និងចិន ក្នុងនោះការបញ្ជាទិញមានទំហំទឹកប្រាក់ ២២០ លានដុល្លារអាមេរិក ជាមួយចិនសម្រាប់ការលក់បន្លែ ផ្លែឈើ និងផលិតផលកសិកម្មផ្សេងទៀត។ ទន្ទឹម នេះ បានពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីដែលនាំទៅដល់ការចាប់ដៃគូក្នុងការបង្កើនគុណភាព និង បរិមាណផលិតផលធានាដល់និរន្តរភាពខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងពេលអនាគត។

## ខ. ការវិនិយោគដោយវិនិយោគិនក្នុង និងក្រៅស្រុក

ក្រោមយុទ្ធនាការ «**គោះទ្វារទាក់ម៉ូយវិនិយោគ**» ដែលជាផ្នែកមួយនៃការទូតសេដ្ឋកិច្ចរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានកៀរគរអ្នកវិនិយោគពីគ្រប់ទិសទីមកវិនិយោគទុននៅកម្ពុជា និងបាន បង្កើតការងារជូនប្រជាពលរដ្ឋឱ្យមានជីវភាពកាន់តែល្អប្រសើរ។



ក្នុងឆ្នាំ២០២៥នេះ រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាសេនាធិការ បានអនុម័តគម្រោងវិនិយោគចំនួន ៦៣០គម្រោង ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ១០ប៊ីលាន ដុល្លារអាមេរិក គឺមានការកើនឡើងចំនួន ២១៦គម្រោង ស្មើនឹងប្រមាណ ៥២% និងទុនវិនិយោគ កើនឡើងប្រមាណ ៣ប៊ីលាន ស្មើនឹងប្រមាណ ៤៥% បើធៀបនឹងឆ្នាំ២០២៤ និងអាចបង្កើតការងារ ថ្មីបានជាង ៤៣៨ពាន់កន្លែង។ ក្នុងសកម្មភាពវិនិយោគទាំងនេះ ត្រូវបានបែងចែកតាមវិស័យ ដូច ខាងក្រោម៖

១. វិស័យឧស្សាហកម្ម មានទុនវិនិយោគសរុបប្រមាណ ៥,៧ប៊ីលាន ដុល្លារអាម៉េរិក។

២. វិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ មានទុនវិនិយោគសរុប ប្រមាណជាង ៣,៨ប៊ីលានដុល្លារអាម៉េរិក។

៣. វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម មានទុនវិនិយោគសរុប ប្រមាណជាង ៤៣៦លានដុល្លារអាម៉េរិក។

៤. វិស័យទេសចរណ៍ មានទុនវិនិយោគប្រមាណ ១៧៥លានដុល្លារ អាម៉េរិក។

## គ. វិស័យការងារ

រាជរដ្ឋាភិបាលតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមចំណែកយ៉ាងសកម្មឆ្លើយតបប្រកបដោយប្រសិទ្ធភាពខ្ពស់ ចំពោះកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-



ដំណាក់កាលទី១ សំដៅលើកកម្ពស់ជីវភាពរស់នៅ បង្កើនប្រាក់ចំណូលការធានាលក្ខខណ្ឌការងារល្អប្រសើរ ការពង្រឹងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ កិច្ចគាំពារសង្គម និងជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ជូនបងប្អូនកម្មករនិយោជិតទាំងក្នុងនិងក្រៅប្រព័ន្ធ និងក្រុមគ្រួសារ ដោយសម្រេចបានលទ្ធផលគួរជាទីមោទនៈ។ ខាងក្រោម គឺជាសមិទ្ធផលជាក់ស្តែងមួយចំនួនក្នុងចំណោមសមិទ្ធផលលេចធ្លោជាច្រើនដែលសម្រេចបាន៖

១. ចាប់ពីខែមករា ឆ្នាំ២០២៥ បានដំឡើងប្រាក់ឈ្នួលអប្បបរមាជូនដល់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប។ ជាមួយនឹងការបន្ថែមចំនួន ២ដុល្លារអាម៉េរិករបស់ **សម្តេចធិបតី** ធ្វើឱ្យប្រាក់ឈ្នួលអប្បបរមាបានកើនដល់ ២០៨ដុល្លារអាម៉េរិក ក្នុងមួយខែ (ឆ្នាំ២០២៤ បាន ២០៤ដុល្លារ) បើបូករួមទាំងប្រាក់អត្ថប្រយោជន៍ជាកាតព្វកិច្ចផ្សេងៗទៀត កម្មករនិយោជិតទទួលបានប្រាក់ឈ្នួលទាបបំផុតចន្លោះពី ២២៥ដុល្លារអាម៉េរិក ដល់

២៣៦ដុល្លារអាម៉េរិក ក្នុងមួយខែ។

២. បានសិក្សា និងរៀបចំដំណើរការបង្កើតទារកដ្ឋាន សម្រាប់កូនៗរបស់កម្មករនិយោជិត ជាលទ្ធផលសហគ្រាសចំនួន ៣ បានស្ម័គ្រចិត្តសាងសង់ទារកដ្ឋាន និងមានរោងចក្រមួយចំនួនផ្សេងទៀតស្ម័គ្រចិត្តបំពេញកាតព្វកិច្ចទំនួលខុសត្រូវសង្គម និងលក្ខខណ្ឌការងារចូលរួមក្នុងការកសាងទារកដ្ឋានបន្ថែមទៀតក្នុងឆ្នាំ២០២៥ នេះ។



៣. បានសហការជាមួយភាគីពាក់ព័ន្ធជំរុញការកសាង និងកែលម្អកន្លែងបរិភោគអាហារ ឬអាហារដ្ឋាននៅតាមសហគ្រាស ជាលទ្ធផលកន្លែងបរិភោគអាហារ ឬអាហារដ្ឋានតាមសហគ្រាសបានកើនឡើងដល់ចំនួន ៤ ០២៦ គិតត្រឹមខែកក្កដា ឆ្នាំ២០២៥ ដែលគិតត្រឹមខែសីហា ឆ្នាំ២០២៣ មានត្រឹមតែ ២ ៧៤៩ ប៉ុណ្ណោះ។

៤. បានសហការជាមួយភាគីពាក់ព័ន្ធសិក្សាយន្តការគាំទ្រ និងលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរជាបណ្តើរៗនូវមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិតឱ្យកាន់តែមានផាសុកភាព និងសុវត្ថិភាពជាងមុន។

៥. គិតត្រឹមខែកក្កដា ឆ្នាំ២០២៥នេះ ក្រសួងបានចុះបញ្ជីទទួលស្គាល់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពនៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ.) សរុបចំនួន ១៥គ្រឹះស្ថានអ្នកវាយតម្លៃដែលចុះបញ្ជីកាសរុបចំនួន ១៤៣នាក់ និងមានអ្នកបានធ្វើតេស្តអនុវត្តទទួលស្គាល់ជំនាញ

នៅតាមមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពសរុបចំនួន ៣ ៨៨៧នាក់។

### ឃ. វិស័យទេសចរណ៍

រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត** ក្រសួងទេសចរណ៍ដែលជាសេនាធិការ បាននិងកំពុងខិតខំប្រឹងប្រែងសហការ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន ប្រទេសដៃគូ អង្គការជាតិ-អន្តរជាតិ និងភាគីពាក់ព័ន្ធនានា ធ្វើឱ្យវិស័យទេសចរណ៍ដែលជា មាសបៃតង របស់កម្ពុជាមានការរីកចម្រើន និងបានចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដោយបានបង្កើតនិងបង្កើនឱកាសការងារនិងមុខរបរ ប្រាក់ចំណូល ជំរុញការនាំចេញនៅនឹងកន្លែង ទាក់ទាញការវិនិយោគ ការអភិរក្សវប្បធម៌ ប្រវត្តិសាស្ត្រ ការការពារធនធានធម្មជាតិ និងលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ។






ជាការពិតដូចទិសស្លោកដែល **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានដាក់ចេញ «**ទេសចរណ៍លូតលាស់ក្នុងសន្តិភាព**» គឺបានបញ្ជាក់ថា កម្ពុជាមិនត្រឹមតែជាទឹកដីប្រកបដោយសម្បត្តិធម្មជាតិ និងបេតិកភណ្ឌ ដូចជាប្រាង្គប្រាសាទ និងតំបន់ធម្មជាតិបៃតងរាប់មិនអស់ ប្រជាជនមានចរិតរួសរាយរាក់ទាក់ មានចិត្តទូលាយស្មោះត្រង់និងប្រកបដោយស្នាមញញឹមប៉ុណ្ណោះទេ ប៉ុន្តែក៏ជាប្រទេសដែលមានសន្តិភាព និងសុវត្ថិភាព ទោះបីជាកម្ពុជាជួបវិបត្តិជម្លោះព្រំដែនដែលបង្កឡើងដោយប្រទេសថៃ កាលពីចុងខែកក្កដា និងទទួលរងនូវការរំលោភបំពានប្រដាប់អាវុធជាថ្មីនៅក្នុងខែធ្នូ ឆ្នាំ២០២៥នេះ ក៏កម្ពុជារក្សាបានការជឿជាក់ពីសំណាក់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ ចំពោះសុខសុវត្ថិភាពរបស់ពួកគេ។

ជាលទ្ធផលក្នុងរយៈពេល ១០ខែ ក្នុងឆ្នាំ២០២៥ នេះ កម្ពុជាអាចរក្សាលំនឹងទេសចរណ៍ដោយទទួលបានភ្ញៀវទេសចរអន្តរជាតិចំនួនជាង ៤,៧៥លាននាក់ ក្នុងនោះភ្ញៀវទេសចរមកពីវៀតណាមឈរនៅលំដាប់លេខរៀងទី១ មានចំនួនជាង ១លាននាក់ ចិនឈរលេខរៀងទី២ មានចំនួន ១លាននាក់។

កម្ពុជា មានក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេសចំនួន ៣៥ ដែលកំពុងតភ្ជាប់ជើងហោះហើរជាមួយ ១៦ប្រទេស និង ៣៩ទីក្រុង ដោយក្នុងនោះបានតភ្ជាប់ទៅកាន់ក្រុង និងប្រទេសចំនួន ៨ ក្នុងតំបន់អាស៊ាន រួមមាន ប្រទេសចិន កូរ៉េខាងត្បូង ឥណ្ឌា កាតា ជប៉ុន និងប្រទេសអេមីរ៉ាតអារ៉ាប់រួម និងតំបន់រដ្ឋបាលពិសេសហុងកុង និងកោះតៃវ៉ាន់។ ក្នុងនោះបានទទួលអ្នកធ្វើដំណើរតាមផ្លូវអាកាសជាង ៥,៧លាននាក់ ពោលគឺមានការកើនឡើង១៤% ធៀបនឹងអំឡុងពេលដូចគ្នា នៅឆ្នាំ ២០២៤ ដែលមានចំនួនត្រឹមតែ ៥លាននាក់។

ដោយមានការជឿទុកចិត្តចំពោះរាជរដ្ឋាភិបាលកម្ពុជាក្នុងការរក្សាសុខសន្តិភាពជូនប្រជាជន



ចំនួនប្រជាពលរដ្ឋក្នុងស្រុកដែលបានធ្វើដំណើរកំសាន្តមានការកើនឡើង គឺមានចំនួន ១៦,១៣លាននាក់ កើនឡើង ៥២,៩%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៤ ហើយទេសចរជាតិធ្វើដំណើរទៅក្រៅមានចំនួន ៩១ម៉ឺននាក់ ថយចុះ ១៤,៩%ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៤។ រីឯចំនួនអាជីវកម្មទេសចរណ៍ ក្នុងរយៈពេល ៧ខែ ឆ្នាំ២០២៥ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានចំនួន ៩ ៦៧៥ កើនឡើង ១៨,៣៩% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៤។

បន្ថែមលើនេះ អាកាសយានដ្ឋានអន្តរជាតិតេជោ ជាសមិទ្ធផលដ៏អស្ចារ្យក្នុងសម័យ **តេជោ-ធិបតី** ត្រូវបានបើកឱ្យដំណើរការជាផ្លូវការ និងជាមោទនភាពសម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបដែល

មានអាកាសយានដ្ឋានលំដាប់អន្តរជាតិ និងជាតម្លៃបន្ថែមខ្ពស់សម្រាប់វិស័យទេសចរណ៍។ ព្រលានយន្តហោះលំដាប់ 4Fនេះ អាចទទួលយន្តហោះខ្នាតធំចុះចតបាន ដូចជា ប្រភេទ AirbusA380 និងប្រភេទ Boeing747 និងអាចទទួលអ្នកដំណើរបានរហូតដល់ ១៣លាននាក់ ក្នុង១ឆ្នាំ ក្នុងដំណាក់កាលទី១។



ដើម្បីធានាបាននូវតួនាទីដ៏សំខាន់នៃវិស័យទេសចរណ៍កម្ពុជាដែលជា មាសបៃតង ក្នុងការចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ក្រសួងបានខិតខំបំពេញបេសកកម្មរបស់ខ្លួនយ៉ាងសកម្ម ដោយសម្រេចបាននូវសមិទ្ធផលសំខាន់ថ្មីៗជាច្រើន លើទិដ្ឋភាពនៃការរៀបចំច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការងារគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងការងារអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ។ ខាងក្រោមនេះជាឧទាហរណ៍ជាក់ស្តែង៖

➢ កិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា បានធ្វើការផ្សព្វផ្សាយទាក់ទាញទេសចរនិងវិនិយោគិនអន្តរជាតិ នាំកម្ពុជាទៅកាន់ពិភពលោក និងនាំពិភពលោកមកទស្សនាកម្ពុជាវិញ ( Bring Cambodia to the World - Bring the World to Cambodia )។

➢ រៀបចំព្រឹត្តិការណ៍និងយុទ្ធនាការផ្សព្វផ្សាយដោយមានភាពច្នៃប្រឌិតនិងឱ្យចំគោលដៅទីផ្សារ ដូចជាយុទ្ធនាការទេសន្តនាកម្ពុជានៅរដូវកាលបៃតង ពិធីបុណ្យសមុទ្រ បុណ្យទន្លេ បុណ្យភ្នំ «ឆ្នាំទេសចរណ៍ កម្ពុជា-ចិន ២០២៥» "ឆ្នាំទេសចរណ៍ កម្ពុជា-ឥណ្ឌា" ជាដើម។

➢ ដើម្បីលើកកម្ពស់និងរក្សា "កិត្តិនាមកម្ពុជា" ឱ្យបានកាន់តែល្អនិងទូលំទូលាយ ក្រសួងក៏បាននិងកំពុងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសរដ្ឋបាលរាជធានីខេត្ត កំណត់និងរៀបចំព្រឹត្តិការណ៍ប្រចាំឆ្នាំ ឱ្យសមស្របតាមអត្តសញ្ញាណនៃរាជធានីខេត្តនីមួយៗ។

## ២.១.៣. ការកសាងហេដ្ឋារចនាសម្ព័ន្ធចម្បងៗ

ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលដែលបានផ្តោតលើគោលនយោបាយអាទិភាពសម្រាប់ការអភិវឌ្ឍ រួមមាន មនុស្ស ផ្លូវ ទឹក ភ្លើង និង



បច្ចេកវិទ្យា ដើម្បីប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ រាជរដ្ឋាភិបាលបានបន្តការកសាងផ្លូវថ្នល់ ផ្លូវល្បឿនលឿន ស្ពាន កំពង់ផែ អាកាសយានដ្ឋានអន្តរជាតិខ្នាតធំទំនើបៗ ទំនប់និងប្រព័ន្ធធារាសាស្ត្រសំខាន់ៗនិងប្រកបដោយសក្តានុពល។ ខាងក្រោមជាសមិទ្ធផលជាក់ស្តែងមួយចំនួនក្នុងចំណោមសមិទ្ធផលជាក់ស្តែងនិងលេចធ្លោជាច្រើន ដែលសម្រេចបាននិងជាទីគួរឱ្យមោទនៈរបស់យើងទាំងអស់គ្នា៖



➢ អាកាសយានដ្ឋានអន្តរជាតិតេជោ ដែលស្ថាបនានៅលើផ្ទៃដីដ៏ល្វឹងល្វើយជាង ២ ៦០០ហិកតា នៅឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងមួយផ្នែកស្ថិតនៅស្រុកបាទី ខេត្តតាកែវ ត្រូវបានបញ្ចប់ជាស្ថាពរនិងសម្ពោធជាផ្លូវការនៅថ្ងៃទី២០

ខែតុលា ឆ្នាំ២០២៥។ ព្រលានយន្តហោះខ្នាតធំ ប្រភេទ 4F ដែលមានផ្លូវយន្តហោះរត់ប្រវែង ៤ គីឡូម៉ែត្រនេះ គឺជាមរតកដ៏មហាសាលនៃគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី សម្រាប់រាជរដ្ឋាភិបាលបន្តវេន និងពលរដ្ឋកម្ពុជាក្នុងការបើកច្រកទ្វារថ្មី ភ្ជាប់កម្ពុជាទៅកាន់ពិភពលោកក្នុងទិសដៅឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។

➢ ស្ថាបនាផ្លូវជាតិ និងផ្លូវខេត្តសរុបចំនួន ៨៥៤ខ្សែ មានប្រវែងសរុប ២០ ៣០៧គ.ម កើនឡើង ២៩១គ.ម ធៀបនឹងឆ្នាំ២០២៣ ដែលមានប្រវែង ២០ ០១៦គ.ម ក្នុងនោះក្រាលកៅស៊ូ និងបេតុងសរុបបានចំនួន ១១ ៦៤៩គ.ម ស្មើនឹង ៥៧,៣៦% នៃប្រវែងផ្លូវសរុប។



➢ ផ្លូវល្បឿនលឿន មានចំនួន ២ខ្សែ ប្រវែងសរុប ៣២២គ.ម ក្នុងនោះ ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ បានបញ្ចប់ការសាងសង់មានប្រវែង ១៨៧គ.ម និងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងបាវិត កំពុងដំណើរការសាងសង់មានប្រវែង ១៣៥គ.ម។ គម្រោងទាំងពីរនេះ គឺស្ថិតក្រោមក្របខ័ណ្ឌកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋ និងឯកជន។

➢ គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ធំៗជាច្រើន បាននិងកំពុងសាងសង់ និងសិក្សាបន្តក្រោមថវិកាហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ ក្នុងនោះរួមមាន៖

❈ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ចំនួន ៦គម្រោង មានប្រវែងសរុប ៣៦០គ.ម ត្រូវបានបញ្ចប់ ក្នុងនោះមាន កំណាត់ផ្លូវជាតិលេខ៧ ផ្លូវជាតិលេខ៣១ ផ្លូវជាតិលេខ៣៣ ផ្លូវជាតិលេខ៤១ ផ្លូវជាតិលេខ ៧១C និង វិថីតេជោសន្តិភាពឆ្នេរអង្កោល

❈ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ចំនួន ១៣គម្រោង មានប្រវែងសរុបចំនួន ៩៤២គ.ម

បាននិងកំពុងអនុវត្តគម្រោងសាងសង់

❈ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ចំនួន ៤១គម្រោង មានប្រវែងសរុប ៣ ២៨៥គ.ម បាន កំពុងធ្វើការសិក្សាគម្រោងសាងសង់

➢ ទំនប់អាងទឹកលេខ២ ដែលមានទីតាំងស្ថិតនៅលើស្ទឹងប្រម៉ោយ ក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ នឹងក្លាយជាអាងស្តុកទឹកធំជាងគេនៅកម្ពុជាដែលអាចមានសមត្ថភាពស្តុកទឹកបានប្រមាណ



៨៦០លានម៉ែត្រគូប អាចស្រោចស្រពលើផ្ទៃដី ចំនួន ២៦ ២០០ហិកតា ដែលនឹងផ្តល់ទឹកប្រើប្រាស់គ្រប់គ្រាន់ក្នុងការពង្រីកវិសាលភាពវិស័យកសិកម្មបន្ថែមទាំងរដូវប្រាំង និងរដូវវស្សា។ គិតត្រឹមចុងខែវិច្ឆិកា ឆ្នាំ២០២៥ គម្រោងនេះសម្រេចបានប្រមាណ ៤០% ដោយបានចាប់ផ្តើមអនុវត្តក្នុងខែមករា ឆ្នាំ២០២៥ ហើយគ្រោងបញ្ចប់នៅក្នុងខែធ្នូ ឆ្នាំ២០២៧។

➢ ទំនប់អាងទឹកវិទ្យាស្ថានតេជោសែន ស្ថិតក្នុងឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ អាចជួយបង្កើនសមត្ថភាពស្រោចស្រពបន្ថែមដល់ផ្ទៃដីដាំដុះដំណាំចំការចំនួន ១៥០ហិកតា ជូនដល់ប្រជាកសិករប្រមាណ ១១៦គ្រួសារ។ ចាប់ពីការផ្តើមអនុវត្តការងារនៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៥ ដល់ថ្ងៃទី១៨ ខែវិច្ឆិកានេះ ការសាងសង់សម្រេចបាន ៣០%។

➢ អាងទឹកដងកាំបិត នៅក្រុងស្ទឹងសែន ខេត្តកំពង់ធំ មានទំនប់ប្រវែង ២ ៦៨០ម៉ែត្រ អាចស្រោចស្រពលើផ្ទៃដីស្រែ ទឹកស្អាត និងកាត់បន្ថយទឹកជំនន់ ដែលជាការផ្តល់ផលប្រយោជន៍ដល់ប្រជាកសិកររស់នៅស្រុកបារាយណ៍ ស្រុកកំពង់ស្វាយ ស្រុកប្រាសាទសំបូរ ស្រុកសណ្តាន់ ស្រុកសន្ទុក និងស្រុកស្ទោងនៃខេត្តកំពង់ធំ។ គិតត្រឹមថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ នេះ វឌ្ឍនភាពនៃការសាងសង់សម្រេចបាន រួមមាន សំណង់បង្ហៀរទឹកដំណាក់កាលទី១ គឺ១០០% សំណង់បង្ហៀរទឹកដំណាក់កាលទី២

៦០% សំណង់មិនបង្ហៀរ ៥៥% ទំនប់ដីខាងឆ្វេង ៩៥% ទំនប់ដីខាងស្តាំ ៧០% និងទ្វារទឹកដំណាក់កាលទី១ សម្រេចបាន១០០%។ អាងទឹកនេះមានទំនប់ដីខាងឆ្វេងប្រវែង ១ ១៣៦ម៉ែត្រ ទំនប់បេតុងប្រវែង៥០ម៉ែត្រ ទំនប់បង្ហៀរទឹកប្រវែង ៣០៦ម៉ែត្រ និងទំនប់ដីខាងស្តាំប្រវែង ១ ១៨៨ម៉ែត្រ។

## ២.១.៤. ការអភិវឌ្ឍវិស័យសង្គមកិច្ច

ដូចគ្នានឹងរាជរដ្ឋាភិបាលអាណត្តិមុនៗដែរ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលមាន **សម្តេចធិបតី ហ៊ុន ម៉ាណែត** ជាប្រមុខ បានប្តេជ្ញាកសាងកម្ពុជាឱ្យក្លាយជាសង្គមជាតិមួយដែលប្រជាជនរស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុភមង្គល និងទទួលបានការគាំពារសង្គមប្រកបដោយសមធម៌ ស្មើសិទ្ធិ ស្មើឱកាស ។



ដើម្បីឈានទៅសម្រេចនូវការប្តេជ្ញាចិត្តដ៏មោះមុតនេះ រាជរដ្ឋាភិបាលដែលមានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាសេនាធិការ បាននិងកំពុងពុះពារប្រែក្លាយគោលនយោបាយ «លើកកម្ពស់កិច្ចគាំពារសង្គម និងសេវាសង្គមដើម្បីលើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច» ឱ្យទៅជាសកម្មភាពជាក់ស្តែង ដើម្បីស្តារជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដោយផ្តោតលើសន្តិសុខស្បៀង ការផ្តល់សេវាសុខាភិបាល ការអប់រំ សេវាសង្គម និងកសាងសំណាញ់សុវត្ថិភាពសង្គម។

គិតត្រឹមខែកក្កដា ឆ្នាំ២០២៥ កម្មវិធីជាតិជំនួយសង្គម បានគ្របដណ្តប់លើពលរដ្ឋសរុបប្រមាណ ១,២លានគ្រួសារ ពលរដ្ឋសរុបប្រមាណ ៤,៨៤ លាននាក់ ស្មើនឹង ២៨% នៃចំនួនពលរដ្ឋសរុប ដោយបានចំណាយថវិការដ្ឋក្នុងទំហំ ១ ១៤០ប៊ីលានរៀល សមមូលប្រមាណ ២៨៥លានដុល្លារ

អាម៉េរិក។ ក្នុងឆ្នាំ២០២៥នេះ រាជរដ្ឋាភិបាលបានវិភាជថវិកាប្រមាណ ២៥៧លានដុល្លារអាម៉េរិក សម្រាប់អនុវត្តកម្មវិធីចំនួន៩។

ជាមួយគ្នានេះ របបសន្តិសុខសង្គម បើគិតត្រឹមខែកក្កដា ឆ្នាំ២០២៥ បានគ្របដណ្តប់លើពលរដ្ឋទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជនសរុបមានប្រមាណ ៣,១លាននាក់ ដោយបានចំណាយថវិកាក្នុងមួយឆ្នាំ សរុបចំនួនប្រមាណ ២ ២៩៧ប៊ីលានរៀល ស្មើនឹងប្រមាណ ៥៧៤លានដុល្លារអាម៉េរិក។ ក្នុងឆ្នាំ២០២៥នេះដែរ រាជរដ្ឋាភិបាលបានវិភាជថវិកាប្រមាណ ៤២៥លានដុល្លារអាម៉េរិក បន្ថែមលើថវិកាវិភាគទានដែលប្រមូលបានពីសមាជិក ប.ស.ស. សម្រាប់អនុវត្តរបបសន្តិសុខសង្គមចំនួន ៣ សំខាន់ៗ ក្នុងនោះរួមមាន ១) របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់កម្មករនិយោជិត មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន, បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ២) របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់កម្មករនិយោជិត និងមន្ត្រីសាធារណៈ និង ៣) របបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់កម្មករនិយោជិត អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

បន្ថែមលើនេះ រាជរដ្ឋាភិបាលបានបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ដែលក្នុងនោះសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះចំនួន ១៩៣ ០៥១នាក់ និងសម្រាប់កុមារអាយុក្រោម ២ឆ្នាំ មានចំនួន ១៦៨ ៤៤១នាក់ ដែលមានថវិកាសរុបប្រមាណ ២០៣ពាន់លានរៀល។ បើគិតត្រឹមខែកក្កដា ឆ្នាំ២០២៥នេះ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ដល់សមាជិក ប.ស.ស. ចំនួន ៦៦៤ ៤៧០នាក់ ជាស្ត្រីមានផ្ទៃពោះ និងចំនួន ៦៩៨ ៣៤១ នាក់ ជាកុមារអាយុក្រោម ២ឆ្នាំ ព្រមទាំងបានចំណាយថវិកាសរុបប្រមាណ ៣៦០ពាន់លានរៀល។



## ២.២. កិច្ចការងារការបរទេស និងទំនាក់ទំនងអន្តរជាតិ

កម្ពុជាប្រកាន់ខ្ជាប់នូវគោលនយោបាយការបរទេសឯករាជ្យ អព្យាក្រឹត និងមិនចូលបក្ខសម្ព័ន្ធ គោរពគ្នាទៅវិញទៅមកដោយស្មើភាព ដោយផ្អែកលើគោលការណ៍នៃច្បាប់អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់ឧត្តមប្រយោជន៍ជាតិខ្មែរ តាមរយៈកិច្ចខិតខំប្រឹងប្រែងបំពេញការងារការបរទេសជាច្រើន ដូចជា ការទូតនយោបាយ ការទូតសេដ្ឋកិច្ច ព្រមទាំងការពង្រឹងមិត្តភាពចាស់និងពង្រីកមិត្តភាពថ្មី ជាដើម។



### ២.២.១. ការទូតនយោបាយ

ជាប្រទេសសន្តិភាពនិយម កម្ពុជាតែងតែព្យាយាមរក្សានិងពង្រឹងទំនាក់ទំនងស្និទ្ធស្នាលជាមួយប្រជាជាតិទាំងអស់ ដោយពង្រឹងការជឿទុកចិត្ត ការយោគយល់គ្នាទៅវិញទៅមក និងភាពជាដៃគូអភិវឌ្ឍន៍ស្មើមុខស្មើមាត់ នៅក្រោមសសរស្តម្ភនយោបាយ-សន្តិសុខ សេដ្ឋកិច្ច និងសង្គម-វប្បធម៌ ឈរលើគោលការណ៍រក្សាសន្តិភាព កសាងនិងពង្រឹងមិត្តភាពនិងកិច្ចសហប្រតិបត្តិការទាំងជាមួយប្រទេសជិតខាង ប្រទេសក្នុងតំបន់ និងប្រទេសនៅលើពិភពលោក។




ទោះបីជាកម្ពុជាទទួលរងការរំលោភបំពានពីសំណាក់ប្រទេសថៃ ក៏រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** នៅតែខិតខំប្រឹងប្រែងបន្តរក្សាជំហរកសាងព្រំដែនសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការដោយប្រើប្រាស់គ្រប់មធ្យោបាយការទូតដើម្បីសម្រេចបានបទឈប់បាញ់ ផ្អែកលើដំណោះស្រាយដោយសន្តិវិធី តាមរយៈការប្រើប្រាស់យន្តការបច្ចេកទេស ដោយអនុលោម

តាមសន្ធិសញ្ញា អនុសញ្ញា និងច្បាប់អន្តរជាតិ។

ជំហរសន្តិភាពនិយម និងភាពសកម្មលើការងារការទូតរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ដោយគោរពនិងអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់អន្តរជាតិ មិនត្រឹមតែទទួលបាននូវការទុកចិត្តនិងការគាំទ្រពីសំណាក់ពលរដ្ឋកម្ពុជាទាំងក្នុងនិងក្រៅប្រទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានលើកមុខមាត់កម្ពុជាលើ



ឆាកអន្តរជាតិ ជាពិសេសទទួលបានការគាំទ្រពីប្រទេសមហាអំណាច និងអាស៊ាន និងបណ្តាមិត្តអន្តរជាតិជាច្រើន ក្នុងបេសកកម្មការពារអធិបតេយ្យភាពជាតិខ្មែរ និងបូរណភាពទឹកដី។ ចំពោះវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់នេះ កម្ពុជាសូមអរគុណជាថ្មីម្តងទៀតចំពោះ ការផ្តួចផ្តើម និងជួយជ្រោមជ្រែងពីសំណាក់ ប្រធានាធិបតីសហរដ្ឋអាមេរិក និងនាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ីនិងជាប្រធានអាស៊ានប្តូរវេន ជាមួយនឹងការចូលរួមយ៉ាងសកម្មរបស់សាធារណរដ្ឋប្រជាមានិតចិន និងការយកចិត្តទុកដាក់របស់បណ្តាប្រទេសជាមិត្ត រួមទាំងអង្គការសហប្រជាជាតិ និងសហភាពអឺរ៉ុប ដែលបានជំរុញឱ្យគោរពកិច្ចព្រមព្រៀងបទឈប់បាញ់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ នៅទីក្រុងពុត្រាចាយ៉ា និងសេចក្តីថ្លែងការណ៍រួមស្តីពីសន្តិភាព ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ នៅទីក្រុងកូឡាឡាំពួ និងសេចក្តីថ្លែងការណ៍រួម នៃកិច្ចប្រជុំពិសេសគណៈកម្មាធិការព្រំដែនទូទៅ (GBC) លើកទី៣ ថ្ងៃទី២៧ ខែធ្នូ ២០២៥ និងជំរុញឱ្យដោះស្រាយបញ្ហាព្រំដែនដោយសន្តិវិធី ដោយផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងរវាងកម្ពុជានិងថៃ ដែលមានជាធរមាន រួមមានអនុសញ្ញា សន្ធិសញ្ញាពាក់ព័ន្ធ និងច្បាប់អន្តរជាតិ។




**ក្នុងតំបន់** ជាសមាជិកអាស៊ាន កម្ពុជាស្វាគមន៍យ៉ាងកក់ក្តៅចំពោះការចូលជាសមាជិកអាស៊ានជាផ្លូវការរបស់ប្រទេសទីម័រឡេស្តេ កាលពីចុងខែតុលា ឆ្នាំ២០២៥ កន្លងទៅនេះ។ ដូចគ្នានឹងសមាជិកអាស៊ានផ្សេងៗទៀត កម្ពុជាបាននិងបន្តចូលរួមយ៉ាងសកម្មក្នុងការពង្រឹងឯកភាពអាស៊ាន និងគាំទ្រចំពោះតួនាទីស្នូលរបស់អាស៊ាន ក្នុងការរក្សាស្ថិរភាពក្នុងតំបន់ ការគាំទ្រការដោះស្រាយជម្លោះដោយសន្តិវិធី និងរួមចំណែកលើកកម្ពស់ផលប្រយោជន៍ និងវិបុលភាពរួមរបស់អាស៊ាន។

**លើឆាកអន្តរជាតិ** ក្នុងនាមជាសមាជិកអង្គការសហប្រជាជាតិ កម្ពុជាបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងអភិបាលកិច្ចសកល គាំទ្រដល់កិច្ចប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងការពង្រឹងការរួមចំណែករបស់ខ្លួនចំពោះកិច្ចការងារស្វែងរកនិងរក្សាសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាពនៅទូទាំងពិភពលោក។

### ២.២.២. ការទូតសេដ្ឋកិច្ច

ក្នុងដំណើរឆ្ពោះទៅសម្រេចឱ្យបានជោគជ័យនូវការប្ដេជ្ញាអភិវឌ្ឍន៍កម្ពុជាឱ្យក្លាយជា «ប្រទេសមានចំណូលខ្ពស់និងមានសេដ្ឋកិច្ចធន់រឹងមាំ» ប្រកបដោយប្រសិទ្ធភាព ភាពប្រកួតប្រជែង បើកចំហ បរិយាបន្ន និងចីរភាព រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** បាននិងកំពុងពង្រីកវត្តមានរបស់ព្រះរាជាណាចក្រកម្ពុជានៅលើទីផ្សារពិភពលោក បង្កើនទំនាក់ទំនងពាណិជ្ជកម្ម ទាក់ទាញអ្នកវិនិយោគ និងអ្នកទេសចរពីបរទេស ដើម្បីជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា។

ជាក់ស្ដែង ទាំងនៅក្នុងប្រទេស ទាំងនៅគ្រប់ដំណើរទស្សនកិច្ចផ្លូវការក្រៅប្រទេស ក៏ដូចជាដំណើរទៅចូលរួមព្រឹត្តិការណ៍អន្តរជាតិថ្នាក់តំបន់និងថ្នាក់ពិភពលោកនានា នៅក្នុងឆ្នាំ២០២៥នេះ



**សម្ដេចធិបតីនាយករដ្ឋមន្ត្រី** តែងតែបានប្រើប្រាស់ឱកាសទាំងក្នុងជំនួបទ្វេភាគី ពហុភាគី និងជំនួបរវាងរដ្ឋនិងវិស័យឯកជន ធ្វើការចរចា និងលើកទឹកចិត្តដើម្បីពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងទាក់ទាញវិនិយោគិនបរទេសមកវិនិយោគនៅកម្ពុជា។ ខាងក្រោមជាឧទាហរណ៍មួយចំនួននៃសកម្មភាពជាក់ស្ដែងដែលមានល្បឿនលឿនដូចព្រួញក្នុងចំណោមសកម្មភាពជាច្រើនដែល **សម្ដេចធិបតី** និងមន្ត្រីអមដំណើរគ្រប់ជាន់ថ្នាក់បានប្រឹងប្រែងសម្រេចបានក្នុងពេលកន្លងមក៖

- **ក្នុងឱកាសចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៦** និងកិច្ចប្រជុំកំពូលពាក់ព័ន្ធកាលពី

ថ្ងៃទី ២៥-២៧ ខែតុលា ឆ្នាំ២០២៥ នៅប្រទេសម៉ាឡេស៊ី **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និងប្រធានាធិបតីសហរដ្ឋអាម៉េរិក ឯកឧត្តម **Donald J. Trump** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មបដិការរវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាម៉េរិក ដើម្បីពង្រឹងនិងពង្រីកពាណិជ្ជកម្មទ្វេភាគី។




ជាមួយគ្នានេះ **សម្តេចធិបតី** បានជួបបណ្តាប្រទេសជាមិត្តជាច្រើន ក្នុងនោះមាន ឡាវ វៀតណាម ម៉ាឡេស៊ី ហ្វីលីពីន ចិន អូស្ត្រាលី នូវែលហ្សេឡង់ កូរ៉េខាងត្បូង បារ៉ែន កូវ៉ែត អូម៉ង់។ល។ ព្រមទាំងបានអនុញ្ញាតឱ្យក្រុមហ៊ុនឯកជនចំនួន ៣ ចូលជួបសម្តែងការគួរសម រួមមាន ក្រុមហ៊ុន Bin Zayed International (M) Berhad ក្រុមហ៊ុន Aurelius HealthCare និងក្រុមហ៊ុន MMAG Holdings Berhad និងក្រុមហ៊ុន NexG Berhad ហើយគ្រប់ជំនួបទាំងអស់គឺដើម្បីជំរុញកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗជាច្រើន ដែលក្នុងចំណោមនោះមាន សេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ។

➢ ក្នុងឱកាសចូលរួមកិច្ចប្រជុំកំពូលអង្គការសហប្រតិបត្តិការសៀងហៃបូកកាលពីថ្ងៃទី៣០ ខែសីហា ដល់ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥ នៅទីក្រុងធានជីន ប្រទេសចិន **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាទ្វេភាគីជាមួយប្រធានាធិបតីសាធារណរដ្ឋប្រជាមានិតចិន ឯកឧត្តម **Xi Jinping** និងបានធ្វើការផ្លាស់ប្តូរយោបល់អំពីការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅលើវិស័យនយោបាយ-ការទូត សេដ្ឋកិច្ច-ពាណិជ្ជកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងវិស័យសំខាន់ៗផ្សេងជាច្រើន។



ជាមួយគ្នានេះ **សម្តេចធិបតី** ក៏បានជួបពិភាក្សាការងារទ្វេភាគីជាមួយថ្នាក់ដឹកនាំកំពូលពីប្រទេសវៀតណាម ឡាវ នេប៉ាល់ ឥណ្ឌា និងបណ្តាថ្នាក់ដឹកនាំនៃប្រទេសជាច្រើន រួមទាំងប្រធានក្រុមប្រឹក្សាភិបាលនិងជាប្រធានធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ដើម្បីពិភាក្សាលើកិច្ចការងារជំរុញវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងទាក់ទាញវិនិយោគិនបរទេសមកកម្ពុជា។

➢ នៅចំពោះមុខបណ្តាក្រុមហ៊ុនវិនិយោគនានា **សម្តេចធិបតី** តែងតែបង្ហាញពីសក្តានុពលវិនិយោគជាមួយនឹងការផ្តល់ជូនអត្ថប្រយោជន៍យ៉ាងច្រើនសម្បូរបែបរបស់កម្ពុជា ដែលផ្តល់នូវកាលានុវត្តភាពប្លែកពីគេ ព្រមទាំងអំណោយផលសម្រាប់ការបោះទុនវិនិយោគ ជាមួយនឹងភាពសម្បូរបែបនៃកម្លាំងពលកម្មវ័យក្មេង និងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសកម្ពុជាស្ថិតនៅទីតាំងយុទ្ធសាស្ត្រចំកណ្តាលនៃអាស៊ាន ងាយស្រួលសម្រាប់ដឹកជញ្ជូន និងការតភ្ជាប់។

ខាងលើគ្រាន់ជាឧទាហរណ៍ខ្លះៗនៃភាពជោគជ័យលើគោលនយោបាយការទូតសេដ្ឋកិច្ចដែលកើតចេញពីជំនួបទ្វេភាគីនិងពហុភាគីដែលប្រព្រឹត្តឡើងនៅក្នុងប្រទេស និងក្រៅប្រទេសរបស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ទាំងនេះ សរបង្ហាញនូវបេសកកម្មការទូតសេដ្ឋកិច្ចដ៏សកម្មនិងភ្លៀវក្លារបស់ **សម្តេច** ក្នុងឆ្នាំទី២ បន្ទាប់ពីបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីក្នុងដំណើរបេសកកម្មការងារផ្លូវការទាំងក្នុងនិងក្រៅប្រទេស ដែលបាននាំមកនូវសមិទ្ធផលថ្មីៗជាច្រើន រួមទាំងផ្នែកការទូតនិងសេដ្ឋកិច្ច ដើម្បីជាឧត្តមប្រយោជន៍ជូនជាតិ មាតុភូមិ និងប្រជាពលរដ្ឋ។

## ២.២.៣. ការទូតពង្រឹងមិត្តភាពចាស់ ពង្រីកមិត្តភាពថ្មី

បេសកកម្មពង្រឹងមិត្តភាពចាស់ពង្រីកមិត្តភាពថ្មី ជាគោលការណ៍នៃនយោបាយការបរទេសរបស់



កម្ពុជា ដែលផ្តួចផ្តើមឡើងតាំងពីសម័យ **សម្តេចតេជោ ហ៊ុន សែន** បន្តរហូតដល់សម័យ **សម្តេចធិបតី ហ៊ុន ម៉ាណែត** បច្ចុប្បន្ន ដោយបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន។ ការទូតពង្រឹងមិត្តភាពចាស់ពង្រីកមិត្តភាពថ្មីនេះ គឺជាអ្វីដែលរាជរដ្ឋាភិបាល

បន្តវេន ដឹកនាំដោយ **សម្តេចធិបតី ហ៊ុន ម៉ាណែត** បាននិងកំពុងបន្តអនុវត្តដោយឥតងាករេ ដ្បិតវាក៏ជាគន្លងនយោបាយការបរទេសសំខាន់ជាងគេមួយដែលអនុម័ត និងតម្រូវឱ្យអនុវត្តដោយគណបក្សប្រជាជនកម្ពុជា។

ការទូតពង្រឹងមិត្តភាពចាស់និងពង្រីកមិត្តភាពថ្មីនេះ មានគោលដៅជាសារវន្តមួយចំនួន នោះគឺបន្តការពារជំហរផ្លូវការរបស់កម្ពុជា នៅលើឆាកអន្តរជាតិ បន្តរក្សាសន្តិភាព បន្តការពារយ៉ាងស្វិតស្វាញឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី និងបន្តជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៃប្រទេសកម្ពុជា។

ពង្រឹងមិត្តភាពចាស់ បានន័យថា ពង្រឹងទំនាក់ទំនងទ្វេភាគីជាមួយបណ្តាប្រទេសដៃគូដែលមានស្រាប់របស់កម្ពុជា ដោយធ្វើការស្តារឡើងវិញ ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យអាទិភាពដើម្បីទាញយកប្រយោជន៍ផ្សេងៗមកជូនប្រជាជាតិខ្មែរ។ ឧទាហរណ៍៖

➢ ជំនួបជាញឹកញាប់រវាងថ្នាក់ដឹកនាំកំពូលកម្ពុជា-ចិន ជាឱកាសដ៏វិសេសវិសាលដែលកម្ពុជាអាចធ្វើការជំរុញភាពរីកចម្រើននៃទំនាក់ទំនងមិត្តភាពដ៏យូរអង្វែង និងជាមិត្តដែកថែបកម្ពុជា-ចិន។ ជាក់ស្តែងជំនួបទ្វេភាគី កម្ពុជា-ចិន កាលពីខែមេសា និងខែកញ្ញា ឆ្នាំ២០២៥ កន្លងទៅនេះ ភាគីទាំងពីរបានឯកភាពជំរុញកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ រួមមាន សេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគ ការពារជាតិនិងសន្តិសុខ អប់រំ បច្ចេកវិទ្យា ឧស្សាហកម្ម និងកសិកម្ម តាមរយៈការជំរុញកិច្ចសហប្រតិបត្តិការ «ច្រករបៀងអភិវឌ្ឍន៍ឧស្សាហកម្ម» និង «ច្រករបៀងមច្ឆានិងអង្ករ» និង ជំរុញការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន ជំរុញវិស័យទេសចរណ៍និងពង្រីកការតភ្ជាប់ជើងហោះហើរត្រង់រវាងកម្ពុជា-ចិន។

➢ ឆ្នាំ២០២៥ គឺជាឆ្នាំដែលទំនាក់ទំនងការទូតរវាងកម្ពុជាជាមួយនឹងសហរដ្ឋអាម៉េរិក មានភាពប្រសើរពីមួយថ្ងៃទៅមួយថ្ងៃ។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏វាងវៃរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានទាក់ទាញការយកចិត្តទុកដាក់ពីសំណាក់រដ្ឋបាល **ប្រធានាធិបតី Donald J. Trump** ជួយជ្រោមជ្រែងស្វែងរកយន្តការដើម្បីឈានទៅសម្រេចបានបទឈប់បាញ់ និងស្វែងរកសន្តិភាពតាមព្រំដែនរវាងកម្ពុជានិងថៃ។ ជាមួយគ្នានេះ ទំនាក់ទំនងការពារជាតិ អប់រំ និងពាណិជ្ជកម្មរវាងកម្ពុជានិងសហរដ្ឋអាម៉េរិកក៏ត្រូវបានពង្រឹងឡើងវិញ ក្នុងនោះរួមមាន ការរៀបចំឡើងវិញនូវសមយុទ្ធអង្គរ ការដក

បម្រាមលក់សព្វាវុធឱ្យកម្ពុជា កិច្ចសហប្រតិបត្តិការរវាងស្ថាប័នសន្តិសុខកម្ពុជា និង FBI ដើម្បីរក្សាសន្តិសុខ និងសុវត្ថិភាពសម្រាប់ប្រជាជន និងប្រទេសទាំងពីរបានបន្តពង្រឹង បង្កើនកៅអីសម្រាប់មន្ត្រីកម្ពុជាសិក្សានៅ West Point និងការទម្លាក់អត្រាពន្ធគយបដិការពី ៤៩% មកត្រឹម ១៩%។

➢ ជាមួយប្រទេសបារាំង តាមរយៈជំនួបពិភាក្សាទ្វេភាគីជាមួយប្រធានាធិបតីបារាំង រដ្ឋាភិបាលបារាំងបានបញ្ជាក់ការគាំទ្រដល់កម្ពុជា ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ ឆ្នាំ២០២៦។ បន្ថែមលើនេះ ថ្នាក់ដឹកនាំកំពូលទាំងពីរ ក៏បានពិភាក្សាអំពីការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យសក្តានុពលមួយចំនួនរួមមានវិស័យពាណិជ្ជកម្មនិងសេដ្ឋកិច្ច ការពារជាតិនិងសន្តិសុខ ថាមពល វប្បធម៌ ជាដើម។



➢ ជាមួយនឹងប្រទេសម៉ាឡេស៊ី កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ មានការវិវត្តរីកចម្រើនជាបន្តបន្ទាប់ ថ្នាក់ដឹកនាំទាំងពីរ បានពិភាក្សាអំពីការបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ ដូចជា វិស័យថាមពល និងហាឡាល់ដោយបានលើកទឹកចិត្តដល់ក្រសួង ស្ថាប័នពាក់ព័ន្ធកម្ពុជានិងម៉ាឡេស៊ី បន្តពិភាក្សាគ្នាឱ្យបានស៊ីជម្រៅបន្ថែមទៀត។

➢ ជាមួយសិង្ហបុរី បន្ថែមលើសមិទ្ធផលជាច្រើន ដែលកើតចេញពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់កម្រិត និងគ្រប់វិស័យ ថ្នាក់ដឹកនាំកំពូលនៃប្រទេសទាំងពីរ បានពិភាក្សានិងឯកភាពគ្នាក្នុងការបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗជាច្រើន រួមមានពាណិជ្ជកម្ម វិនិយោគនិងហិរញ្ញវត្ថុ ការតភ្ជាប់ប្រជាជននិងប្រជាជន ការពារជាតិនិងសន្តិសុខ កសិកម្ម សន្តិសុខស្បៀងនិងថាមពល និងការបណ្តុះបណ្តាលជំនាញនិងវិជ្ជាជីវៈ។

➢ ជាមួយហ្វីលីពីន ប្រមុខថ្នាក់ដឹកនាំទាំងពីរបានពិភាក្សាគ្នាពង្រឹងវិស័យសក្ដានុពលសំខាន់ៗមួយចំនួន ជាអាទិ៍ ឌីជីថល បច្ចេកវិទ្យា និងបញ្ញាសិប្បនិម្មិត (AI) សហគ្រាសមីក្រូធុនតូចនិងមធ្យម (MSMEs) ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក សេវាកម្មថែទាំសុខភាព ទេសចរណ៍ ព្រមទាំងវិស័យសន្តិសុខនិងការពារជាតិ។

➢ ជាមួយសាធារណរដ្ឋកូរ៉េ ជាដៃគូយុទ្ធសាស្ត្រ ដែលមានកិច្ចសហប្រតិបត្តិការរីកចម្រើនគួរឱ្យកត់សម្គាល់ស្ទើរគ្រប់វិស័យ ថ្នាក់ដឹកនាំទាំងពីរបានឯកភាពជាមួយនឹងគំនិតផ្តួចផ្តើមបង្កើតក្រុមការងារចំពោះកិច្ចចម្រុះកម្ពុជា-កូរ៉េ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការរវាងសមត្ថកិច្ចនៃប្រទេសទាំងពីរក្នុងការប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋនានាដែលពាក់ព័ន្ធជាមួយជនជាតិកូរ៉េនៅកម្ពុជា រួមទាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដោយផ្តោតលើការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវព័ត៌មានអំពីលទ្ធផលវិជ្ជមាននៃកិច្ចសហប្រតិបត្តិការកម្ពុជា-កូរ៉េ។

ចំពោះការពង្រីកមិត្តភាពថ្មី បានន័យថា សកម្មភាពទាក់ទាញឬបើកផ្លូវទទួលដៃគូទ្វេភាគីថ្មីដែលអាចផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។ ឧទាហរណ៍៖

➢ ជាមួយប្រទេសកូវ៉ែត **សម្តេចធិបតី** បានស្វាគមន៍បំណងរបស់ប្រទេសកូវ៉ែតក្នុងការពង្រឹងចំណងមិត្តភាពរវាងប្រទេសទាំងពីរ ដែលស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរឹតចំណង និងពង្រីកទំនាក់ទំនងជាមួយបណ្តាប្រទេសនៅមជ្ឈិមបូព៌ា តាមរយៈការជំរុញកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗ ដូចជា ពាណិជ្ជកម្ម ទេសចរណ៍ និងការតភ្ជាប់រវាងប្រជាជននិងប្រជាជន។

➢ ជាមួយប្រទេសបារ៉ែន ប្រទេសទាំងពីរបានគាំទ្រគំនិតផ្តួចផ្តើមបង្កើតយន្តការពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ ដើម្បីរួមចំណែកជំរុញកិច្ចសហប្រតិបត្តិការកម្ពុជា-បារ៉ែន។ ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរបានឯកភាពគ្នាចំពោះលក្ខខណ្ឌដែលប្រទេសទាំងពីរអាចបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ក្នុងនោះរួមមានការផ្គត់ផ្គង់អាលុយមីញ៉ូម សម្រាប់វិស័យសំណង់។

➢ ជាមួយប្រទេសអូម៉ង់ មានសក្តានុពលច្រើនក្នុងការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យជាច្រើនទៀត ហើយក្រសួងពាណិជ្ជកម្មកម្ពុជាបាននិងកំពុងខិតខំស្វែងរកឱកាស និងការផ្សារ

ភ្ជាប់ទំនាក់ទំនងបន្ថែមទៀត ដើម្បីជំរុញទំហំពាណិជ្ជកម្ម និងទាក់ទាញការវិនិយោគបន្ថែមពីតំបន់មជ្ឈិមបូព៌ារួមទាំងប្រទេសអូម៉ង់។

➤ ជាមួយតាជីគីស្ថាន ថ្នាក់ដឹកនាំទាំងពីរ គ្រោងនឹងអញ្ជើញបំពេញទស្សនកិច្ចផ្លូវការទៅវិញទៅមកនាពេលវេលាសមស្របខាងមុខ ព្រមទាំងបានប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរ ដើម្បីបន្តផ្សារភ្ជាប់ទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធ។

## ៣. កម្មវិធីគោលនយោបាយអាទិភាពទាំង៦

រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា នៅក្នុងឆ្នាំទីពីរនេះ បាននិងកំពុងបន្តបំពេញបេសកកម្មរបស់ខ្លួនយ៉ាងសកម្មនិងប្រកបដោយថាមពល ដែលជាកម្លាំងចលករ ជំរុញការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពទាំង ៦ ចំណុច ឱ្យកាន់តែមានសន្ទុះទៅមុខជានិច្ចដោយសម្រេចបានសមិទ្ធផលធំៗជាច្រើន ក្នុងការគាំពារ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋក្រីក្រ និងងាយរងហានិភ័យដែលមានចំណូលទាប ឱ្យទទួលបាននូវការថែទាំសុខភាព ការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ ជំនួយសង្គម លទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងការគាំទ្រពីមន្ត្រីបច្ចេកទេសកសិកម្មនិងទីផ្សារ ដើម្បីធានាថាប្រជាពលរដ្ឋកម្ពុជាទាំងនោះកាន់តែមានជីវភាពធូរធារ មានចំណេះជំនាញច្បាស់លាស់យ៉ាងតិចមួយក្នុងជីវិត និងមានសុខភាពកាន់តែល្អប្រសើរដែលជាទុននាំកម្ពុជាឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។



### ៣.១. ផ្តល់ការថែទាំសុខភាពឆ្ពោះទៅការគ្របដណ្តប់ជាសកល

ការពង្រីកសេវាសុខាភិបាលឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកល ជាកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការបម្រើសេវាថែទាំសុខភាព និងសុខុមាលភាពជូនប្រជាពលរដ្ឋស្របតាមគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចឱ្យបានការគ្របដណ្តប់សុខភាពជា



សកលនៅកម្ពុជា ឆ្នាំ២០៣៥ និងតាមបំណងប្រាថ្នាធំបំផុតមួយ គឺគ្មានពលរដ្ឋណាម្នាក់ត្រូវបានទុកចោលនៅពេលឈឺដោយមិនទទួលបានសេវាសុខាភិបាល ដោយសារគ្មានប្រាក់ព្យាបាលនោះឡើយ។

ដើម្បីសម្រេចបាននូវការប្តេជ្ញានេះ រាជរដ្ឋាភិបាលបានខិតខំធ្វើការងារសំខាន់ពីរទន្ទឹមគ្នា ពោលគឺដៃម្ខាងផ្តល់ជូនបណ្ណព្យាបាលជំងឺជូនប្រជាពលរដ្ឋ និងដៃម្ខាងទៀតប្រឹងប្រែងធ្វើកំណែទម្រង់វិស័យសុខាភិបាលឱ្យមានសមត្ថភាពរឹងមាំទាំងធនធានមនុស្ស សម្ភារបរិក្ខារសុខាភិបាល និងហិរញ្ញវត្ថុ ដើម្បីធានាឱ្យការផ្តល់សេវាសុខាភិបាលងាយស្រួល លឿនរហ័ស មានប្រសិទ្ធភាព គុណភាព និងដោយឥតបង់ប្រាក់។

តាមរយៈគោលនយោបាយនេះ ប្រជាពលរដ្ឋប្រមាណ ៨លាននាក់ កំពុងកាន់បណ្ណព្យាបាលសុខភាពដោយឥតបង់ថ្លៃ ក្នុងនោះប្រជាពលរដ្ឋដែលកំពុងកាន់បណ្ណមូលនិធិសមធម៌សុខាភិបាល មកពីគ្រួសារក្រីក្រ គ្រួសារងាយរងហានិភ័យ កម្មករ-និយោជិតក្រៅប្រព័ន្ធ កីឡាករ កីឡាការិនី បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ សមាគមម៉ូតូរ៉ឺម៉កកង់បី អ្នកធាក់ស៊ីក្លូ បុគ្គលិក និងអ្នកជំនាញបោសសម្អាតមីន មានចំនួន ៤,៧លាននាក់។

រាជរដ្ឋាភិបាល បានបន្តពង្រឹងការផ្តល់សេវា និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន ដល់កម្មករនិយោជិត មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការ អតីតយុទ្ធជន បុគ្គលស្វ័យនិយោជន៍និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ជាប្រចាំ ដោយផ្នែកថែទាំសុខភាព ជាផ្នែកធំជាងគេមានសមាជិកចុះបញ្ជីកាថ្មីបន្ថែមមានចំនួនប្រមាណជាង ៦៦ម៉ឺននាក់ ធ្វើឱ្យសមាជិក ប.ស.ស. សរុបបានកើនឡើងដល់ជាង ៣,៤៧លាននាក់ (គិតត្រឹមបំណាច់ខែវិច្ឆិកា ឆ្នាំ២០២៥)។ ទន្ទឹមគ្នានេះ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត សម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. មាន

សមាជិកសរុបចំនួនប្រមាណ ៨២ម៉ឺននាក់ ដោយបុគ្គលស្វ័យនិយោជន៍មានចំនួនប្រមាណ ៥៧ម៉ឺននាក់ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. មានចំនួនប្រមាណ ២៥ម៉ឺននាក់។

តាមរយៈគោលនយោបាយនេះ ប្រជាពលរដ្ឋកំពុងកាន់បណ្ណសមាជិក ប.ស.ស. ដែលមានសុពលភាព អាចប្រើប្រាស់សេវាសម្រាប់ព្យាបាលសុខភាពដោយឥតបង់ថ្លៃ។ ដោយឡែក ប្រជាពលរដ្ឋដែលកំពុងកាន់បណ្ណមូលនិធិសមធម៌សុខាភិបាលដែលបោះពុម្ពដោយ ប.ស.ស. កម្មករនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ កីឡាករ កីឡាការិនី បុគ្គលបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ សមាគមម៉ូតូរ៉ឺម៉កកង់បី អ្នកធាក់ស៊ីក្លូ មានចំនួនប្រមាណជា ១៤ម៉ឺននាក់។

ជាមួយនឹងការផ្តល់បណ្ណថៃទាំសុខភាព និងព្យាបាលជំងឺដោយឥតបង់ប្រាក់ រាជរដ្ឋាភិបាលបានទម្លាក់ថវិកាជាង ៧,៥លានដុល្លារ នៅឆ្នាំ២០២៤ និងថវិកាពិសេសបន្ថែមជិត ២០លានដុល្លារសហរដ្ឋអាមេរិក នៅឆ្នាំ២០២៥ និងឆ្នាំបន្ទាប់ដូចគ្នា ដើម្បីទិញថ្នាំសម្រាប់ព្យាបាលជំងឺលើសឈាម និងជំងឺទឹកនោមផ្អែម ដើម្បីកាត់បន្ថយការចំណាយ និងពេលវេលារបស់ប្រជាពលរដ្ឋ។ បន្ថែមពីនេះ រាជរដ្ឋាភិបាលបានសម្រេចផ្តល់ថវិកាជិត២០លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៥ ដើម្បីពង្រឹងសមត្ថភាពវះកាត់ និងសង្គ្រោះបន្ទាន់ (ICU) នៅមន្ទីរពេទ្យបង្អែកស្រុកកម្រិត២ តាមរយៈការបំពាក់ឧបករណ៍ សម្ភារៈ ដូចជាម៉ាស៊ីនវិភាគឈាម វិភាគជីវៈគីមី និងអ៊ិចសារ៉េជាដើម។



សរុបមកការអនុវត្តកម្មវិធីគោលនយោបាយនេះ បានផ្តល់ផលប្រយោជន៍យ៉ាងធំធេងសម្រាប់ប្រជាពលរដ្ឋ ជួយកាត់បន្ថយការចំណាយលើថ្លៃព្យាបាល ចំណេញពេលវេលា និងកាន់តែទទួលបានសុខភាពល្អ និងសុខុមាលភាពល្អប្រសើរ ដែលនេះជាក្តីសង្ឃឹមរបស់ប្រជាពលរដ្ឋគ្រប់ៗរូប។

## ៣.២. បណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈដល់កូនអ្នកក្រីក្រនិងងាយរងហានិភ័យ

កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ដល់យុវជនក្រុមគោលដៅមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ នៅទូទាំងប្រទេសចំនួនប្រមាណ ១,៥លាននាក់ ក្នុងកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ កំពុងត្រូវបានអនុវត្តយ៉ាងសកម្មដោយរាជរដ្ឋាភិបាលតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលជាសេនាធិការ។

តាមរយៈគោលការណ៍ រៀនឱ្យចប់ ឱ្យចេះ និងឱ្យមានការងារធ្វើ រៀនដោយឥតបង់ថ្លៃ និងរៀនដោយមានប្រាក់ឧបត្ថម្ភ។ កម្មវិធីនេះទទួលបានការគាំទ្រ និងការចាប់អារម្មណ៍ចុះឈ្មោះចូលរៀន



យ៉ាងច្រើនពីសំណាក់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ។ សិស្សដែលបញ្ចប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ទទួលបានចំណេះជំនាញពិតប្រាកដ ច្បាស់លាស់ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រនានា និងបានយកចំណេះជំនាញទៅបង្កើតមុខរបរផ្ទាល់ខ្លួនថែមទៀត។

ជាលទ្ធផលគិតត្រឹមខែតុលា ឆ្នាំ២០២៥ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលអ្នកស្នើចុះឈ្មោះចូលរៀនចំនួន ១៤៥ ៤១២នាក់ ដោយមានសិស្សកំពុងសិក្សាចំនួន ១៤ ៩០៤ នាក់ និងសិស្សបានបញ្ចប់ការសិក្សាមានចំនួន ៧២ ៣២២នាក់ និងបានជំរុញការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងសរុបចំនួន ២៧ ៥៨៤នាក់។ សិស្សដែលបញ្ចប់វគ្គបណ្តុះបណ្តាល ទទួលបានការងារធ្វើចំនួន ៣៥ ៦៧៧នាក់ ដែលនេះជាការរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពការងារ កំណើនផលិតភាព អភិវឌ្ឍន៍សង្គម កាត់បន្ថយភាពក្រីក្រ និងពន្លឿនកំណើនសេដ្ឋកិច្ចជាតិ។

## ៣.៣. ពង្រឹងកម្មវិធីជាតិជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ និងងាយរងហានិភ័យ

ការអនុវត្តកម្មវិធីជាតិជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ និងងាយរងហានិភ័យ បានបង្ហាញយ៉ាងច្បាស់អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការជួយដល់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទក្នុងសង្គម ជាពិសេស កុមារកំព្រា កុមារងាយរងគ្រោះ ស្ត្រីអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ជនចាស់ជរា ជនមានពិការភាព អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល។



ក្នុងការប្រែក្លាយគោលនយោបាយឱ្យក្លាយជាសកម្មភាពជាក់ស្តែង រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារចំនួនបួន ក្នុងនោះរួមមាន (១) ការឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ (២) កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រថ្នាក់បឋមនិងមធ្យមសិក្សាចំណេះទូទៅ (៣) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ជនមានពិការភាព និង (៤) កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ជនចាស់ជរាអាយុ៦០ឆ្នាំឡើង។

ជាលទ្ធផល ចាប់តាំងពីចាប់ផ្តើមអនុកម្មវិធីពីខែមេសា ឆ្នាំ២០២៤ ដល់ ខែវិច្ឆិកា ឆ្នាំ២០២៥ ប្រជាពលរដ្ឋជាអ្នកទទួលផលមានគ្រួសារគោលដៅសរុបចំនួន ៧៥៩ ៤១២គ្រួសារ ចំណាយថវិកាចំនួន ៨១៥ពាន់លានរៀល ស្មើនឹងទំហំប្រមាណ ២០៣,៨៦លានដុល្លារអាមេរិក ស្ត្រីមានផ្ទៃពោះចំនួន ១០០ ៣៤៣នាក់ កុមារអាយុក្រោម២ឆ្នាំចំនួន ១៥២ ២២៣នាក់ ចំណាយថវិកាចំនួន ៨១ពាន់លានរៀល ស្មើប្រមាណ ២០,៣៨លានដុល្លារអាមេរិក។

បន្ថែមពីលើនេះទៀត រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះ ស្ត្រីសម្រាលកូន និងកូនអាយុក្រោម២ឆ្នាំ មានអ្នកទទួលផលសរុបចំនួន ១៣៤នាក់ ក្នុងនោះស្ត្រីមានផ្ទៃពោះចំនួន ៤៩នាក់ ស្ត្រីសម្រាលកូនចំនួន ៣នាក់ និងកូនអាយុក្រោម២ឆ្នាំចំនួន ៨២នាក់ ដោយចំណាយថវិកាចំនួន ៤២,២លានរៀល គិតពីថ្ងៃទី៩ ខែកក្កដា ដល់ខែវិច្ឆិកា ឆ្នាំ២០២៥។

កម្មវិធីថ្មីនេះ បានចូលរួមលើកកម្ពស់សុខុមាលភាពមាតា និងទារក ព្រមទាំងរួមចំណែក ដោះស្រាយកង្វះខាតអាហារូបត្ថម្ភរបស់កូនតាមម្ដាយនៅក្នុងពន្ធនាគារចាប់តាំងពីកូនក្នុងផ្ទៃ រហូតដល់អាយុ ២ឆ្នាំ សំដៅជំរុញការលូតលាស់ ទាំងកាយសម្បទា និងបញ្ញាស្មារតី។

ជារួមគោលនយោបាយ «ការលើកកម្ពស់កិច្ចគាំពារសង្គម និងសេវាសង្គមដើម្បីលើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច» បានចូលរួមចំណែកលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងសមធម៌ សេវាសង្គមកិច្ច និងកិច្ចគាំពារសង្គមសម្រាប់គ្រួសារក្រីក្រ ជនរងគ្រោះ និងងាយរងគ្រោះយ៉ាងមានប្រសិទ្ធភាព។

## ៣.៤. យុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ

យុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ បាននិងកំពុងក្លាយជាឧបករណ៍យុទ្ធសាស្ត្រដ៏សំខាន់ ក្នុងការលើកកម្ពស់លទ្ធភាព និងប្រសិទ្ធភាពនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅក្នុងប្រព័ន្ធជាជំហានៗ ក្នុងគោលដៅឆ្លើយតបទៅនឹងសេចក្ដីត្រូវការ និងការធ្វើអន្តរាគមន៍ទីផ្សារប្រកបដោយស័ក្ដិសិទ្ធិភាព ប្រសិទ្ធភាព និងចីរភាព ជាពិសេសដើម្បីធានាឱ្យសេដ្ឋកិច្ចក្រៅប្រព័ន្ធកាន់តែមានលទ្ធភាពនិងសក្ដានុពល និងបានរួមចំណែកពេញលេញក្នុងដំណើរការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ខណៈសេដ្ឋកិច្ចក្រៅប្រព័ន្ធរួមចំណែកធំធេងទៅក្នុងសេដ្ឋកិច្ចជាតិ ប្រមាណ ២៦,៤% នៃផលិតផលក្នុងស្រុកសរុប។



រាជរដ្ឋាភិបាលបានកំណត់វិស័យ និងប្រភេទអាជីវកម្ម មុខរបរ និងការងារអាទិភាពចំនួន ១៥ ប្រភេទ និងបែងចែកជា ៣តំបន់ ដូចជា ទី១. តំបន់សេដ្ឋកិច្ចក្រៅប្រព័ន្ធ ទី២. តំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ និង ទី៣. តំបន់សេដ្ឋកិច្ចក្នុងប្រព័ន្ធ ដើម្បីកាត់បន្ថយហានិភ័យនៃការធ្វើអាជីវកម្ម និងការប្រកបមុខរបរនៅកម្ពុជាឱ្យបានជាអតិបរមា និងជាពិសេសដើម្បីជំរុញឱ្យមានបរិយាកាសធុរកិច្ចកាន់តែ

ល្អប្រសើរ និងទាក់ទាញនៅកម្ពុជា។

ផ្អែកលើភាពចាំបាច់ខាងលើនេះ រាជរដ្ឋាភិបាលបានបង្កើនការយកចិត្តទុកដាក់ និងផ្តល់អាទិភាពខ្ពស់លើការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈការពង្រឹងសមត្ថភាព ភាពប្រកួតប្រជែង និងភាពធន់នៃមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលជាកម្លាំងចលករដ៏សំខាន់ និងប្រកបដោយសក្តានុពលដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និងវិសមភាពសង្គម។

ទាំងនេះគឺជាការគិតគូរផ្តល់ភាពកក់ក្តៅជូនបងប្អូនអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យទទួលបានកញ្ចប់អត្ថប្រយោជន៍និងកិច្ចអន្តរាគមន៍ចាំបាច់នានារបស់រាជរដ្ឋាភិបាល ដែលក្នុងនោះរួមមាន ការផ្តល់កញ្ចប់អត្ថប្រយោជន៍ផ្នែកពន្ធដារនិងការចុះឈ្មោះ កញ្ចប់អត្ថប្រយោជន៍ផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ កញ្ចប់អត្ថប្រយោជន៍ផ្នែកគាំពារសង្គម និងកញ្ចប់អត្ថប្រយោជន៍ផ្នែកធនាគារ ដើម្បីរួមចំណែកលើកកម្ពស់ជីវភាព អនាគតមុខរបរ ការងារ និងប្រាក់ចំណូលគ្រួសារ ក្នុងគោលដៅឆ្លើយតបទៅនឹងតម្រូវការលើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច ដែលជាមូលដ្ឋានគ្រឹះ និងជាមធ្យោបាយដ៏សំខាន់ចាំបាច់ក្នុងការសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។

តាមរយៈការដាក់ឱ្យដំណើរការជាផ្លូវការ «ថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ» មានអ្នកស្នើសុំចុះឈ្មោះចំនួន ៧៩ ១៥៥នាក់ ឬអង្គភាព ដែលក្នុងនោះការស្នើដែលត្រូវបានអនុម័តមានចំនួន ៦៥ ៥៨៩ ពោលគឺស្មើនឹងជិត ៨៣% នៃអ្នកស្នើសុំសរុប គិតត្រឹមថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥។

## ៣.៥. លើកស្ទួយផលិតកម្មកសិកម្ម រកទីផ្សារ និងការរក្សាលំនឹងតម្លៃកសិផល

ការលើកស្ទួយផលិតកម្ម ការស្វែងរកទីផ្សារសម្រាប់កសិផល និងការរក្សាបានលំនឹងថ្លៃកសិផលរបស់ប្រជាកសិករក្នុងកម្រិតសមរម្យ គឺជាអាទិភាពរបស់រាជរដ្ឋាភិបាលច្រើនអាណត្តិមុនៗ និងបានបន្តមកដល់រាជរដ្ឋាភិបាល អាណត្តិទី៧ នៃរដ្ឋសភា។

តាមរយៈក្រុមការងារចម្រុះសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម រាជរដ្ឋាភិបាល

បានបញ្ចេញហិរញ្ញប្បទានពិសេសជាបន្តបន្ទាប់ចំនួន៣លើក មានទំហំទឹកប្រាក់ចំនួន ៩៨,៥៥លានដុល្លារអាម៉េរិក ដើម្បីរក្សាសន្តិសុខស្បៀង និងរក្សាស្ថិរភាពថ្លៃទំនិញ។ ជាមួយគ្នានេះ ដើម្បីអន្តរាគមន៍



រក្សាលំនឹងថ្លៃស្រូវក្នុងរដូវប្រមូលផលក្នុងខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២៥ និងដើមឆ្នាំ២០២៦ខាងមុខនេះ រាជរដ្ឋាភិបាលបានសម្រេចបញ្ចេញមូលនិធិចំនួន ៤០លានដុល្លារអាម៉េរិក បន្ថែមជាលើកទី៥ ក្រោមកម្មវិធីហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល ដើម្បីលើកស្ទួយផលិតផលកសិកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផល តាមរយៈធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម សម្រាប់ផ្តល់ឥណទានជាទុនបង្វិលដល់រោងម៉ាស៊ីនកិនស្រូវដៃគូ ប្រមូលទិញស្រូវពីបងប្អូនប្រជាកសិករឱ្យអស់លទ្ធភាពនិងតម្លៃសមរម្យ។ វិធានការនេះបានជួយឱ្យរោងម៉ាស៊ីនអាចប្រមូលទិញស្រូវពីកសិករបានទាន់ពេលវេលា និងរក្សាតម្លៃល្អសម្រាប់កសិករ ព្រមទាំងបានធានាស្តុកអង្ករគ្រប់គ្រាន់សម្រាប់ការនាំចេញ។

តាមរយៈការចុះពន្យល់ផ្សព្វផ្សាយដោយផ្ទាល់ស្តីពីទស្សនទាននៃសហគមន៍កសិកម្មទំនើបជូនដល់ប្រជាកសិករជាច្រើនម៉ឺននាក់នៅទូទាំងប្រទេស ធ្វើឱ្យប្រជាកសិករកាន់តែច្រើនឡើងៗចាប់អារម្មណ៍លើសហគមន៍កសិកម្មទំនើប និងបានស្នើសុំបង្កើតជាសហគមន៍កសិកម្មទំនើបនៅក្នុងតំបន់របស់ខ្លួន។




ត្រឹមខែវិច្ឆិកា ឆ្នាំ២០២៥ មានសហគមន៍កសិកម្មទំនើបចំនួន ២៦ ត្រូវបានរៀបចំបង្កើតឡើងនៅក្នុងខេត្តចំនួន ១១ លើមុខដំណាំយុទ្ធសាស្ត្រចំនួន ៤មុខ គឺ ស្រូវ បន្លែ ស្វាយចន្ទី និងម្រេច ខណៈសហគមន៍កសិកម្មនិងសហគមន៍កសិកម្មទំនើប

នៅទូទាំងប្រទេសកម្ពុជា មានចំនួនសរុបប្រមាណ ១ ៤៧៦សហគមន៍ ដែលមានកសិករសមាជិកសរុបចំនួន ១៩៧ ៤៤៥នាក់ និងមានដើមទុនសរុបចំនួនប្រមាណជាង ១៩៥,៦៨ប៊ីលានរៀល។ សហគមន៍កសិកម្មទំនើបចំនួន ១០ ទទួលបានប្រាក់កម្ចីពីធនាគាររីង ធនាគារ FTB និងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម( ARDB ) សរុបជាទឹកប្រាក់ចំនួនប្រមាណជាង ៣,៦៦លានដុល្លារអាម៉េរិក ក្នុងអត្រាការប្រាក់ ៨%/ឆ្នាំ រួចហើយ និងគ្រោងនឹងស្នើសុំកម្ចីឥណទានបន្ថែមសរុបចំនួនប្រមាណ ៨,៧លានដុល្លារអាម៉េរិក បន្ថែមទៀត។

ជាលទ្ធផល ប្រជាកសិករសមាជិកសហគមន៍កសិកម្មទំនើបមានចិត្តសប្បាយរីករាយ និងពេញចិត្តចំពោះគោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាលស្តីពីសហគមន៍កសិកម្មទំនើប ដោយកសិករទទួលបានការគាំទ្រដើមទុនជាឥណទាន និងបច្ចេកទេសកសិកម្មពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងទទួលបានទីផ្សារជាងមុន តាមរយៈការធ្វើកិច្ចសន្យាផលិតកម្មកសិកម្មតាមកិច្ចសន្យា។

## ៣.៦. ការដាក់ពង្រាយអ្នកជំនាញបច្ចេកទេសកសិកម្មតាមឃុំ-សង្កាត់

កម្មវិធីគោលនយោបាយដើម្បីលើកស្ទួយវិស័យកសិកម្ម តាមរយៈការដាក់ពង្រាយអ្នកជំនាញបច្ចេកទេសកសិកម្មតាមឃុំ-សង្កាត់ បាននិងកំពុងអនុវត្តដោយរលូននិងមានប្រសិទ្ធភាព និងមានការ



ចូលរួមខ្ពស់ពីប្រជាកសិករ និងអ្នកពាក់ព័ន្ធយ៉ាងសកម្ម។ មន្ត្រីកសិកម្មបានចុះផ្ទាល់ទៅដល់ភូមិដ្ឋាន ១០ ៩៨៣ភូមិ ដែលស្មើនឹង ៩៩% នៃភូមិគោលដៅ ហើយកសិករដែលបានស្គាល់មន្ត្រីកសិកម្មឃុំមានចំនួន ៥៦៧ ៩៦៦គ្រួសារ ហើយមន្ត្រីកសិកម្មឃុំបានចូលរួមដោះស្រាយបញ្ហាប្រឈមក្នុងមូលដ្ឋានចំនួន ៥០ ០៧៣ករណី។

ឧទាហរណ៍ជាក់ស្តែង មន្ត្រីកសិកម្មឃុំនៅខេត្តព្រះវិហារ បានសម្របសម្រួលស្វែងរកទីផ្សារល្ពៅ

ជូនប្រជាកសិករនៅក្នុងខេត្តព្រះវិហារ ដោយសហការជាមួយក្រសួងពាណិជ្ជកម្ម ផ្សារទំនើប និងសប្បុរសជននានា ក្នុងបរិមាណល្ពៅចំនួន ១ ៥៨០តោន ដែលបានជួយទាញតម្លៃល្ពៅឱ្យឡើងថ្លៃពី ១២០រ/គ.ក ទៅ៣០០រ/គ.ក។ មន្ត្រីកសិកម្មឃុំខេត្តកោះកុង បានសម្របសម្រួលស្វែងរកទីផ្សារបន្លែជូនប្រជាកសិករ ជាពិសេសស្ពៃជើងទា ឬស្ពៃជ្រក់ក្នុងបរិមាណប្រមាណជាង ២០តោន។ លើសពីនេះទៀតមន្ត្រីកសិកម្មឃុំ ជាពិសេសខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ដូចជាខេត្តព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ និងកោះកុង បានជំរុញចលនាដាំដំណាំជុំវិញផ្ទះ ដើម្បីផ្គត់ផ្គង់ដល់ជីវភាពគ្រួសារកសិករផង និងដើម្បីត្រៀមសម្រាប់ការប្រើប្រាស់និងផ្គត់ផ្គង់ដល់កងទ័ពផង។

គិតមកដល់ឆ្នាំ២០២៥នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយក្រសួងមុខងារសាធារណៈ បានរៀបចំការប្រឡងជ្រើសរើសមន្ត្រីកសិកម្មឃុំបន្ថែមចំនួន ៣៧២នាក់ សម្រាប់ការដាក់ពង្រាយបន្ថែមបង្គ្រប់ ១ ៦០០នាក់ នៅក្នុងឃុំគោលដៅអាទិភាពកសិកម្ម ក្នុងនោះឃុំដែលត្រូវដាក់ពង្រាយមាន ១ ៥០៩ឃុំ។

ជារួមកម្មវិធីគោលនយោបាយអាទិភាពទី៦ របស់រាជរដ្ឋាភិបាលដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសេនាធិការ បានជួយឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ដើម្បីចូលរួមសម្រេចចក្ខុវិស័យប្រទេសកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

## ៤. វិធានការគន្លឹះទាំង៥

ក្នុងដំណើរឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្លាយជាប្រទេសមានចំណូលខ្ពស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត** បានដាក់ចេញនូវវិធានការគន្លឹះចំនួន៥ សម្រាប់



ដោះស្រាយបញ្ហាប្រឈមជាអាទិភាពដែលជាឥទ្ធិពលនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ សង្គ្រាមពាណិជ្ជកម្ម ការគាំពារនិយម ជាតិនិយម ការប្រែប្រួលអាកាសធាតុ និងប្រជាសាស្ត្រ។ វិធានការគន្លឹះចំនួន៥ នោះរួមមាន (១) ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ (២) ការលើកកម្ពស់គុណភាពអប់រំ (៣) ការលើកកម្ពស់

គុណភាពសេវាសុខាភិបាល (៤) ការពង្រឹងការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ប្រយុទ្ធប្រឆាំងនឹងការជួញដូរនិងប្រើប្រាស់គ្រឿងញៀន និង (៥) ការពង្រឹងនិងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។

**១-ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ៖** ក្រសួងមុខងារសាធារណៈក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល បានធ្វើការយ៉ាងសកម្មក្នុងការធានាឱ្យបាននូវ (១) ជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព (២) ការរៀបចំនិងកែលម្អរចនាសម្ព័ន្ធក្រសួង ស្ថាប័ន តាមរយៈការអនុវត្តការវិភាគមុខងារនិងការធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិល និង (៣) ការពង្រឹងការគ្រប់គ្រង ការវិវឌ្ឍអាជីពរបស់មន្ត្រីរាជការ និងការអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន ការកែលម្អការផ្តល់សេវាសាធារណៈ ការកែទម្រង់ប្រព័ន្ធបៀវត្ស ដើម្បីបង្កើនប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងរបបសន្តិសុខសង្គម។



ខាងក្រោមគឺជាសមិទ្ធផលជាក់ស្តែងមួយចំនួនក្នុងចំណោមសមិទ្ធផលជាច្រើនដែលក្រសួងសម្រេចបាននាពេលកន្លងមកនេះ រួមមាន៖

➢ បានរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីឱ្យចូលបម្រើការតាមក្រសួង ស្ថាប័នចំនួន ៤លើក រួមមាន ទី១. ការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ បេក្ខជនជាប់ជាស្ថាពរសរុបចំនួន ៣៥៧នាក់ (ស្ត្រី ១៦៥នាក់) ទី២. ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ចំនួន ១៥កន្លែង ក្នុងក្របខណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី បេក្ខជនជាប់ជាស្ថាពរសរុបចំនួន ១៤នាក់ (ស្ត្រី ៤នាក់) ទី៣. ការប្រឡងប្រជែងជ្រើសរើសមន្ត្រីការទូតជាន់ខ្ពស់ បេក្ខជនជាប់ជាស្ថាពរសរុបចំនួន ៤៦នាក់ (ស្ត្រី ១៩នាក់) និង ទី៤. ការប្រឡងប្រជែងជ្រើសរើសមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ ឱ្យចូលបម្រើការងារសម្រាប់មុខតំណែងវិជ្ជាជីវៈសុខាភិបាល បេក្ខជនជាប់ជាស្ថាពរសរុបចំនួន ៣៤១នាក់ (ស្ត្រី ២៤៨នាក់)។

➢ គិតត្រឹមថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥ បានសម្រេចការជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈបានចំនួន ១៩រាជធានី-ខេត្ត ក្នុងចំណោម ២៥រាជធានី-ខេត្ត សរុបចំនួន ២ ៧២២នាក់ និងតាមអង្គភាពសុខាភិបាលមូលដ្ឋាននៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិរបស់រដ្ឋបាលរាជធានីខេត្ត បានចំនួន ១៩រាជធានី-ខេត្ត ក្នុងចំណោម ២៥រាជធានី-ខេត្ត សរុបចំនួន ១ ៤៦៣នាក់។



➢ រៀបចំដំឡើងប្រាក់បៀវត្ស ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភប្រចាំខែជូនមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ យោធិននៃកងយុទ្ធពលខេមរភូមិន្ទ មន្ត្រីជាប់កិច្ចសន្យា ក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីភូមិ សម្រាប់ឆ្នាំ២០២៥។

**២-ការលើកកម្ពស់គុណភាពអប់រំ៖** ធ្វើការអភិវឌ្ឍសាលារៀនឱ្យក្លាយជាអង្គភាពផ្តល់សេវាសាធារណៈដែលប្រកបដោយប្រសិទ្ធភាពខ្ពស់ អភិបាលកិច្ចល្អ និងមានគណនេយ្យភាព គឺជាអាទិភាពចម្បងមួយរបស់រាជរដ្ឋាភិបាលក្នុងការកសាងមូលធនមនុស្ស ដើម្បីចូលរួមជាមួយរដ្ឋាភិបាលក្នុងការសម្រេចបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការ បានធ្វើប្រតិបត្តិការយ៉ាងសកម្មក្នុងការពង្រឹងអភិបាលកិច្ចសាលារៀន និងការលើកកម្ពស់សកម្មភាពបង្រៀន និងរៀន តម្រង់ឆ្ពោះទៅរកការកែលម្អលទ្ធផលនៃការសិក្សារបស់សិស្សឱ្យបានកាន់តែប្រសើរឡើង ប្រកបដោយវិន័យ សីលធម៌ គុណធម៌ និងឥរិយាបថថ្លៃថ្នូរ ស័ក្តិសមជាកុលបុត្រ កុលធីតាខ្មែរ និងជាមូលធនមនុស្សដែលជាទំពាំងស្នងឬស្សីរបស់ជាតិ។



ក្នុងកិច្ចប្រឹងប្រែងនេះ ក្រសួងបាននិងកំពុងបន្តអនុវត្តកំណែទម្រង់សាលារៀន និងបន្តកែលម្អយន្តការចុះជួយគាំទ្រសាលារៀនគំរូ ដោយប្រើប្រាស់ថវិការដ្ឋ និងថវិកាដៃគូអភិវឌ្ឍន៍ធ្វើការផ្តោតជាពិសេសលើលទ្ធផលសិក្សារបស់សិស្ស និងវិធីសាស្ត្របង្រៀននិងរៀន ការបណ្តុះបណ្តាល និងការគាំទ្រដល់គណៈគ្រប់គ្រងសាលារៀន ការចូលរួមរបស់សហគមន៍ និងការពង្រឹងគណនេយ្យភាពរបស់សាលារៀន។

ជាលទ្ធផល សាលារៀនចំនួន ១៤៤ បានជាប់ស្តង់ដាជាសាលារៀនគំរូ។ សាលាទាំងនោះរួមមាន សាលាមត្តេយ្យសិក្សាចំនួន ២៤ សាលាបឋមសិក្សាចំនួន ៥០ អនុវិទ្យាល័យចំនួន ៥ វិទ្យាល័យចំនួន ៦០ និងសាលាគរុកោសល្យចំនួន ៥។ ជាមួយគ្នានេះ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំរបស់រាជរដ្ឋាភិបាល បានពង្រីកសាលារៀនគោលដៅក្នុងឆ្នាំសិក្សា ២០២៤-២០២៥ ដល់សាលាបឋមសិក្សាចំនួន ១៦១ ក្នុង២៥រាជធានី-ខេត្ត ដោយផ្តោតលើកម្មវិធីក្រៅម៉ោងសិក្សាចំនួន ២ម៉ោងបន្ថែម រួមមាន វិន័យ សីលធម៌ ចរិយាធម៌ ការងារស្ម័គ្រចិត្ត និងការចូលរួមពីសហគមន៍។

**៣-ការលើកកម្ពស់គុណភាពសេវាសុខាភិបាល៖** ដើម្បីធានាបាននូវការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន រាជរដ្ឋាភិបាលដែលមានក្រសួងសុខាភិបាលជាសេនាធិការ បាននិងកំពុងខិតខំធ្វើការពង្រឹងសមត្ថភាពផ្តល់សេវានៅមូលដ្ឋានមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក។ ជាមួយគ្នានេះ ក្រសួងប្រឹងប្រែងធ្វើការអភិវឌ្ឍសមត្ថភាពស្ថាប័នសុខាភិបាល រួមមាន ការគ្រប់គ្រងធនធានមនុស្សនិងហិរញ្ញវត្ថុ ការធ្វើទំនើបកម្មសម្ភារៈ បរិក្ខារពេទ្យ ការងារនិយ័តកម្ម ដើម្បីឆ្លើយតបការគម្រាមកំហែងសុខភាពសាធារណៈ និងគ្រោះអាសន្នសុខភាព ព្រមទាំងលើកកម្ពស់សុខភាពនៃកិច្ចដំណើរការមុខងារស្ថាប័ន និងកសាងភាពជាដៃគូរឹងមាំរវាងវិស័យសុខាភិបាលសាធារណៈ និងឯកជន ដើម្បីធានាឱ្យប្រជាជនទទួលបានសេវាថែទាំសុខភាពដែលប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។



ក្រសួងសុខាភិបាលបានបន្តបង្កើនការអភិវឌ្ឍធនធានមនុស្ស បង្កើនសមត្ថភាពបុគ្គលិកនិងមន្ត្រីសុខាភិបាល នូវជំនាញបច្ចេកទេសទៅតាមតម្រូវការ និងឆ្លើយតបបញ្ហាសុខភាពរបស់សហគមន៍ ព្រមទាំងបង្កើនសមត្ថភាពក្នុងការគ្រប់គ្រង និងដឹកនាំប្រកបដោយភាពបុរេសកម្ម និងនវានុវត្តន៍ ជាពិសេសបានបង្កើនសមត្ថភាពសេវាសង្គ្រោះបឋម នៅតាមមណ្ឌលសុខភាព សេវាសង្គ្រោះបន្ទាន់ និងសេវាវះកាត់នៅមន្ទីរពេទ្យបង្អែកស្រុក និងពង្រឹងប្រព័ន្ធបញ្ជូនអ្នកជំងឺ និងជួយសង្គ្រោះអាយុជីវិតជនរងគ្រោះបានទាន់ពេល។

**៤-ការពង្រឹងការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរនិងប្រើប្រាស់គ្រឿងញៀន៖** ការធានាបាននូវសន្តិសុខ សុវត្ថិភាព និងភាពសុខសាន្តនៅក្នុងភូមិដ្ឋានរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់ច្រកល្ហក គឺជាកិច្ចការចម្បងដែលរាជរដ្ឋាភិបាលកម្ពុជាទាំងសម័យ **សម្ដេចតេជោ** បន្តដល់សម័យ **សម្ដេចធិបតី** បាននិងបន្តយកចិត្តទុកដាក់ព្រមទាំងបានដាក់ចូលក្នុងវិធានការគន្លឹះ ទាំង៥ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ កម្មវិធីពង្រឹងគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព និងបានប្រគល់ភារកិច្ចនេះដល់ក្រសួងមហាផ្ទៃ ដែលជាសេនាធិការដើម្បីដឹកនាំអនុវត្ត។



ដូចឆ្នាំមុនៗ ក្នុងឆ្នាំ២០២៥ ក្រសួងមហាផ្ទៃបាននិងបន្តបំពេញបេសកកម្ម តួនាទី ភារកិច្ចរបស់ខ្លួនបានយ៉ាងខ្ជាប់ខ្ជួនក្នុងការពង្រឹងប្រសិទ្ធភាពការងារបម្រើសេវារដ្ឋបាលសាធារណៈ សន្តិសុខ សណ្ដាប់ធ្នាប់សង្គម ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ប្រយុទ្ធប្រឆាំងបទល្មើសគ្រប់ប្រភេទ និងការអភិវឌ្ឍមូលធនមនុស្ស។ ការលើកកម្ពស់វិធានការជំនាញក្នុងការអនុវត្តគោលនយោបាយ ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព គឺជាសមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលជាច្រើនដែលក្រសួងសម្រេចបានជោគជ័យ និងជាជំហានៗ។ ជាក់ស្ដែង ការបង្ក្រាបនិងការអប់រំកែលម្អក្មេងទំនើងបានធ្វើឡើងយ៉ាងសកម្មក្រោមបទបញ្ជារបស់ **សម្ដេចធិបតី ហ៊ុន ម៉ាណែត** រីឯការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ដែលបានធ្វើយ៉ាងសកម្មតាមរយៈយុទ្ធនាការ និងវិធានការជាបន្តបន្ទាប់ដូចភ្លៀងរលឹម គ្រឿងញៀនជាច្រើនត្រូវបាន

រឹបអូស ខណៈដែលអ្នកជួញដូរឬអ្នកពាក់ព័ន្ធជាច្រើនត្រូវបានឃាត់ខ្លួន ជាមួយគ្នានេះ ល្បែងស៊ីសងខុសច្បាប់ ល្បែងអនឡាញ ក៏ត្រូវបានចាត់វិធានការជាបន្តបន្ទាប់។




និយាយជារួម រាជរដ្ឋាភិបាលបន្តវេនមិនត្រឹមតែអាចធានាបាននូវការផ្ដល់ជូនប្រទេសជាតិនិងប្រជាពលរដ្ឋនូវសុខសន្តិភាពជៀសផុតពីសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែក៏ធានាបាននូវការផ្តល់ជូនប្រជាពលរដ្ឋនូវសន្តិសុខ សុវត្ថិភាព និងភាពសុខសាន្ត ទាំងពេលធ្វើដំណើរ ទាំងនៅភូមិឋានរស់នៅ ដែលនេះបានចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅ និងភាពសុខដុមរមនារបស់ប្រជាពលរដ្ឋ និងសង្គមជាតិ។

ទន្ទឹមនឹងនេះ កិច្ចការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក៏ត្រូវបានកត់សម្គាល់ជាវិជ្ជមានចំពោះវឌ្ឍនភាព និងការសម្រេចបានសមិទ្ធផលនានាជាច្រើន ក្នុងនោះរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំនិងពង្រឹងជាបន្តបន្ទាប់ទាំងក្នុងការអភិវឌ្ឍស្ថាប័ន ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងប្រសិទ្ធភាពនៃការអនុវត្តការងារដើម្បីធានាដល់ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋានឆ្លើយតបនឹងតម្រូវការ និងការដោះស្រាយបញ្ហាប្រឈមជូនប្រជាពលរដ្ឋបានទាន់ពេល និងចំគោលដៅនៃបញ្ហា។

តាមរយៈការកែទម្រង់នេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗកាន់តែមានសមត្ថភាព និងលទ្ធភាពក្នុងការផ្តល់សេវា និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រីឯការផ្ទេរមុខងារត្រូវបានធ្វើឡើងជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជាជំហានៗ។ ជាក់ស្តែង បច្ចុប្បន្នមុខងារចំនួនពីរ គឺវិស័យសុខាភិបាល និងអប់រំ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទាំងនេះបង្ហាញយ៉ាងច្បាស់នូវការយកចិត្តទុកដាក់ និងផ្តល់អាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល នីតិកាលទី៧។

**៥-ការពង្រឹងនិងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌៖** ក្នុងស្មារតីគាំទ្រនិងប្តេជ្ញាសម្រេចឱ្យបាននូវឆន្ទៈដ៏មោះមុតរបស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** ក្នុងការពង្រឹងប្រសិទ្ធភាព




នៃប្រព័ន្ធយុត្តិធម៌ ក្រសួងយុត្តិធម៌បាននិងកំពុងខិតខំប្រឹងប្រែងបំពេញបេសកកម្មរបស់ខ្លួនយ៉ាងសកម្ម ដើម្បីធានាបាននូវគុណភាពនៃការផ្តល់យុត្តិធម៌ឱ្យបានកាន់តែសុក្រឹត្យ និងផ្តល់សេវាយុត្តិធម៌ឱ្យកាន់តែរហ័ស និងកាន់តែល្អប្រសើរជូនប្រជាពលរដ្ឋ ព្រមទាំងរួមចំណែកលើកកម្ពស់វប្បធម៌សន្តិភាពនិយម គួរជាទីមោទនៈ។ ខាងក្រោមជាបេសកកម្មចំនួន ៣ ក្នុងចំណោមបេសកកម្មចម្បងៗជាច្រើន ដែលក្រសួងបាននិងកំពុងអនុវត្ត និងសម្រេចជោគជ័យបានជាជំហានៗ៖

➢ ទី១. ការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បន្ថែមលើយន្តការដែលមានស្រាប់ ដើម្បីជួយសម្រុះសម្រួលដោះស្រាយវិវាទឱ្យបានឆាប់រហ័ស ជាពិសេសវិវាទរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ជាមួយគ្នានេះ អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក.) បានសម្រេចបង្កើតឱ្យមានការិយាល័យតំណាង អ.ដ.ក. ចំនួន៤ នៅតាមខេត្តចំនួន ៤ នៅភាគឦសានបន្ថែមទៀត ដែលជាផ្នែកមួយនៃការអនុវត្តគម្រោងចុះដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅតំបន់ជនជាតិដើមភាគតិច និងតំបន់ដាច់ស្រយាល។ ជាលទ្ធផល តាមរយៈ អ.ដ.ក. បានទទួលសំណុំរឿងសរុប ១ ៨៦៨ករណី ចំពោះសំណុំរឿងដែលបានដោះស្រាយដោយជោគជ័យមាន ៤៤៩ករណី ហើយសំណុំរឿងដែលបានបិទបញ្ចប់ដោយភាគីមិនសះជា មាន ២៦២ករណី និងសំណុំរឿងដែលបានលើកចោលដោយសារខុសសមត្ថកិច្ចចំនួន ៩៧ករណី និងកំពុងពិនិត្យ និងដោះស្រាយចំនួន ៨០៨សំណុំរឿង គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៥។

➢ ទី២. ការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការឱ្យបានឆាប់រហ័ស សំដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ។

➢ ទី៣. ការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ សំដៅជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ក៏ដូចជាលើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវនៅក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្តីដោយតុលាការ។

## ៥. សេចក្តីសន្និដ្ឋាន



កិច្ចខិតខំប្រឹងប្រែងក្នុងការរក្សាសុខសន្តិភាពនិងការពារបានអធិបតេយ្យភាពជាតិ បូរណភាពទឹកដី ការផ្តល់តម្លៃដល់ជីវិតមនុស្សនិងភាពសុខសាន្តរបស់ប្រជាពលរដ្ឋជាធំ និងការរក្សាបាននូវលំនឹងសេដ្ឋកិច្ច គឺជាស្នូលនៃនយោបាយសន្តិភាពនិយមរបស់រាជរដ្ឋាភិបាលកម្ពុជាបន្តវេន ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដែលបានតម្កល់ “សន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខ” ជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងមនុស្សជាតិ និងជាត្រីវិស័យក្នុងការប្រែក្លាយប្រទេសកម្ពុជាឱ្យក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់ ក្នុងឆ្នាំ២០៥០។ ទាំងនេះគឺជាគុណ

តម្លៃដែលមិនអាចកាត់ថ្លៃបានរបស់រាជរដ្ឋាភិបាលមុនៗ ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបន្សល់ទុកជាកេរមរតកដ៏វិសេសវិសាល គឺសុខសន្តិភាព ស្ថិរភាពនយោបាយ និងកិច្ចអភិវឌ្ឍ ដែលបានបង្កលក្ខខណ្ឌល្អប្រសើរសម្រាប់រាជរដ្ឋាភិបាលបន្តវេនអាចបន្តបោះជំហានទៅមុខបានយ៉ាងស្វាហាប់ប្រកបដោយជំនឿចិត្ត ឆ្ពោះទៅសម្រេចការអភិវឌ្ឍប្រទេសលើគ្រប់វិស័យ។

ជាក់ស្តែងតាមរយៈយុទ្ធសាស្រ្ត **ស្វាត់តែមិនស្មៀម** របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ដែលដៃម្ខាងពង្រឹងវិស័យការពារជាតិ និងដៃម្ខាងទៀតបានខិតខំប្រឹងប្រែងប្រើប្រាស់គ្រប់មធ្យោបាយក្នុងការការពារសន្តិភាព អធិបតេយ្យភាព និងបូរណភាពទឹកដី ដោយផ្អែកលើកិច្ចសន្ទនាការទូត និងអនុលោមតាមសន្ធិសញ្ញា អនុសញ្ញា និងច្បាប់អន្តរជាតិ។

ក្នុងកិច្ចអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច កម្ពុជាបានរក្សាកំណើនជាតិ ក្នុងអត្រា ៥% នៅឆ្នាំ២០២៥ ដែលនេះបានឆ្លុះបញ្ចាំងនូវភាពវាងវៃរបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ដែលអាចធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានភាពធន់ ទោះស្ថិតក្នុងបរិការណ៍ដែលប្រឈមនឹងការវិវត្តដ៏ស្មុគស្មាញនៃសភាពការណ៍ ក្នុងតំបន់ អន្តរជាតិ និងកត្តាអវិជ្ជមានជាច្រើនទៀត។ ជាក់ស្តែងទោះបីកម្ពុជាជួបវិបត្តិជម្លោះព្រំដែនដែលបង្កឡើងដោយប្រទេសថៃ រាជរដ្ឋាភិបាលកម្ពុជានៅរក្សាបានចរន្តពាណិជ្ជកម្មនាំចេញនាំចូលរបស់ខ្លួនដោយរក្សាបានកំណើនសេដ្ឋកិច្ចបានល្អ។

ក្រោមយុទ្ធនាការ «គោះទ្វារទាក់ម៉ូយវិនិយោគ» ដែលជាផ្នែកមួយនៃការទូតសេដ្ឋកិច្ចរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានកៀរគរអ្នកវិនិយោគពីគ្រប់ទិសទីមកវិនិយោគទុននៅកម្ពុជា និងបានបង្កើតការងារជូនប្រជាពលរដ្ឋឱ្យមានជីវភាពកាន់តែល្អប្រសើរ។

ស្របតាមទិសស្លោក «ទេសចរណ៍លូតលាស់ក្នុងសន្តិភាព» របស់ **សម្តេចធិបតី** ប្រជាជាតិលើពិភពលោកកាន់តែច្រើនឡើងៗ បានទទួលស្គាល់ថា កម្ពុជាមិនត្រឹមតែជាទឹកដីប្រកបដោយសម្បត្តិធម្មជាតិ និងបេតិកភណ្ឌ និងមានប្រជាជនដែលរួសរាយរាក់ទាក់ ស្មោះត្រង់ និងប្រកបដោយស្នាមញញឹមប៉ុណ្ណោះទេ ប៉ុន្តែក៏ជាប្រទេសដែលមានសន្តិភាព និងសុវត្ថិភាព ទោះបីជារងការរំលោភបំពានពីប្រទេសថៃក៏ដោយ ក៏កម្ពុជាអាចរក្សាបាននូវសន្តិសុខជូនភ្ញៀវទេសចរក្នុងការធ្វើដំណើរកំសាន្តលើទឹកដីកម្ពុជាផងដែរ។

ជារួមក្នុងឆ្នាំ២០២៥នេះ ទោះបីកម្ពុជាជួបនឹងបញ្ហាប្រឈមមួយចំនួនដែលជាឥទ្ធិពលនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ សង្គ្រាមពាណិជ្ជកម្ម ការគាំពារនិយម ជាតិនិយមជ្រុល ការប្រែប្រួលអាកាសធាតុ ប្រជាសាស្ត្រ និងជាពិសេសការរំលោភបំពានរបស់ប្រទេសថៃ ក៏រាជរដ្ឋាភិបាលកម្ពុជានៅតែអាចរក្សាបានលំនឹងសេដ្ឋកិច្ច ស្ថិរភាពនយោបាយ សន្តិភាព និងអាចសម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើន ជាពិសេសការងារពាណិជ្ជកម្ម ការទាក់ទាញអ្នកវិនិយោគ ការកសាងគ្រប់គ្រងនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធនិងប្រព័ន្ធគាំពារសង្គម រក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបានធ្វើកំណែទម្រង់លើវិស័យធំៗជាច្រើនដូចជា សុខាភិបាល រដ្ឋបាលសាធារណៈ អប់រំ កសិកម្ម ការលើកកម្ពស់គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព គុណភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ជាដើម។

ទាំងនេះបញ្ជាក់យ៉ាងច្បាស់ ពីកិច្ចខិតខំប្រឹងប្រែងរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និងមន្ត្រីក្រោមឱវាទគ្រប់ជាន់ថ្នាក់ដែលបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានយ៉ាងខ្ជាប់ខ្ជួនក្នុងការប្រែក្លាយគោលនយោបាយនានាឱ្យទៅជាសកម្មភាពជាក់ស្តែង ដើម្បីដឹកនាំនាវាកម្ពុជាឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់៕



# សូមថ្លែងអំណរគុណ

អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល (អ.អ.រ) សូមថ្លែងអំណរគុណជាពិសេសដល់អ្នកថតរូបនៃក្រសួងនិងស្ថាប័នទាំងអស់ដែលបានផ្តល់រូបថតដល់ អ.អ.រ សម្រាប់ប្រើប្រាស់ក្នុងកូនសៀវភៅនេះ រួមមាន៖

◎ ក្រុមការងារផេកសម្តេចព្រះមហាអរិយវង្ស បណ្ឌិត យ៉ន សេងយៀត

◎ ក្រុមការងារផេកសម្តេចតេជោ ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា

◎ ក្រុមការងារផេកសម្តេចធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

◎ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

◎ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

◎ ក្រសួងពាណិជ្ជកម្ម

◎ ក្រសួងមហាផ្ទៃ

◎ ក្រសួងមុខងារសាធារណៈ

◎ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

◎ ក្រសួងសាធារណការ និងដឹកជញ្ជូន

◎ ក្រសួងសុខាភិបាល

◎ ក្រសួងទេសចរណ៍

◎ ក្រសួងអប់រំ យុវជន និងកីឡា

◎ ក្រសួងយុត្តិធម៌

◎ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

◎ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

◎ រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន

◎ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

◎ មន្ទីរព័ត៌មានខេត្តពោធិ៍សាត់

◎ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP)

អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល